ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Mar-2016, 13:22
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី៣៨៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ម៉ាទីន ខារ៉ុបគីន

*(Judge Martin KAROPKIN)*

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ង

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផនៈ**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីៈ**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការៈ**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាឡិចសាន់ដឺ ហ៊ីនតុន (2-TCE-88) | អង់គ្លេស |
| លោក នួន ជា | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក អាឡិចសាន់ដឺ ហ៊ីនតុន** (2-TCE-88)

សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី............................................................ ទំព័រ ៧

សួរដោយលោក គង់ សំអុន ផ្តើមពី ...................................................................... ទំព័រ ៣៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ហ៊ីនតុន បញ្ចប់។ ហើយមុននឹងដំណើរការ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីទាំងអស់ថា នៅក្នុងកិច្ចដំណើរការសវនាការនៅព្រឹកនេះដោយលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ គាត់មានបញ្ហាសុខភាព មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបាន ហើយបន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ម៉ាទីន ខារ៉ុបគីន ដែលជាចៅក្រមបម្រុងអន្តរជាតិ ជំនួយកន្លែងចៅក្រម ក្លូឌា ហ្វេនស៍ ដែលអវត្តមាន។ ហើយការអនុវត្តនេះ យោងតាមបទប្បញ្ញត្តិនៃវិធាន៩៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

កញ្ញា ជា ស៊ីវហ៉ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់របស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ អ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺលោក ហ៊ីនតុន។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៨:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ យើងសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន

អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និង ដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះ និងវិលមុខ នៅពេលអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទបញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៩:២៨]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

បាទ កុំអាលទាន់!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីណ្សៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីទាំងអស់។ ខ្ញុំសូមលើកឡើងជាសង្ខេបទេ ទាក់ទងទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យកោះហៅសាក្សីពាក់ព័ន្ធទៅនឹង

សវនាការផ្នែកនៅមន្ទីរសន្តិសុខភ្នំប្រុសភ្នំស្រី គឺឯកសារ E390។ មេធាវីការពារក្តី ខៀវ សំផន បានឲ្យមានការពិភាក្សាពាក់ព័ន្ធត្រង់ចំណុចនេះនៅថ្ងៃចន្ទ ហើយយើងខ្ញុំសូមឲ្យមានពេលវេលាបន្ថែមសម្រាប់ពិនិត្យមើលទៅឯកសារនេះ។ ហើយបន្ទាប់ពីអ្នកជំនាញបញ្ចប់ការសួរដោយក្រុមមេធាវីការពារក្តី ខៀវ សំផន យើងខ្ញុំសូមពិចារណាចំណុចនេះនៅរសៀលនេះ។ នេះគឺជាសំណើសុំរបស់យើងខ្ញុំ ដើម្បីឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅបានឆាប់រហ័ស។ នេះគឺជាសំណើសុំទី្ពមួយ។

[០៩:១១:០៥]

លោកប្រធាន ទាក់ទងទៅនឹងអ្នកជំនាញរូបនេះ ខ្ញុំសូមលើកចំណុចមួយដើម្បីធ្វើម៉េចឲ្យនីតិវិធីព្រឹកនេះមានដំណើរការរលូន និងជឿនលឿនទៅមុខ។ យើងឃើញថាអ្នកជំនាញអាចឆ្លើយតបទៅនឹងឯកសារខ្លះបាននៅក្នុងស្ថានភាពណាមួយនោះដែលមិនមានការបង្ហាញសម្រង់ ឬក៏ផ្នែកណាមួយទៅឲ្យគាត់មើលនោះទេ។

យើងបានផ្តល់ឯកសារយ៉ាងច្រើនទៅដល់អ្នកជំនាញ នៅថ្ងៃទី០៧ តាំងពីថ្ងៃទី០៧ ខែមីនា ក៏ប៉ុន្តែយើងមិនបានផ្តល់ ERN ឲ្យចំទំព័រមួយៗដែលចង់សួរនោះទេ ដោយសារថាឯកសារដែលបានផ្តល់ជូនគាត់មានប្រមាណប្រហែលជា៤.០០០ទំព័រឯណោះ។ ដូច្នេះយើងខ្ញុំយល់ឃើញថា បើសិនណាជាយើងអានឯកសារទាំងអស់នោះឲ្យអ្នកជំនាញស្តាប់សិន ក៏មិនមានពេលវេលាដែរ។ ហើយមេធាវីការពារក្តី ខៀវ សំផន នេះក៏នឹងស្រង់យកសម្រង់ជាក់លាក់ណាមួយមកសួរអ្នកជំនាញដែរ។ យើងខ្ញុំដឹងថាយើងខ្ញុំមិនមានពេលវេលាច្រើនទេ ហើយមេធាវីការពារក្តី ខៀវ សំផន ចង់តាំងសំណួរឲ្យបានលឿនឆាប់រហ័ស ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងការព្រួយបារម្ភមួយចំនួនដែលអ្នកជំនាញបានលើកឡើងកាលពីម្សិលមិញថាគាត់មានការលំបាកក្នុងការឆ្លើយទៅនឹងភស្តុតាងមួយចំនួនដែលគាត់មិនបានឃើញពីមុនមក ព្រោះយើងទើបតែនឹងបង្ហាញគាត់នៅក្នុងសវនាការនេះទេ។ ដូច្នេះមេធាវីការពារក្តីខៀវ សំផន គឺបានផ្តល់នូវឯកសារលេខ E3 ក៏ដូចជា ERN មកដល់ភាគីទាំងអស់ផង មិនត្រឹមតែអ្នកជំនាញទេ ដូច្នេះដើម្បីឲ្យវាដំណើរការទៅបានលឿន។ ហើយដោយយោងទៅលើប្រព័ន្ធជាមូលដ្ឋានរបស់យើង និងដើម្បីបង្កជាលក្ខណៈឲ្យអ្នកជំនាញផ្តល់នូវគំនិតយោបល់ពាក់ -- គឺថាសូមឲ្យផ្តល់ព័ត៌មានបន្ថែមទៅឲ្យគាត់ផងនៅពេលណាដែលយើងបង្ហាញឯកសារទៅចំពោះមុខអ្នកជំនាញ។ ជាពិសេសដើម្បីជួយដល់អ្នកជំនាញសូមបង្ហាញកាលបរិច្ឆេទ បើសិនណាជាឯកសារនោះបានពីសម័យកាលនោះ ចំណងជើងឯកសារ តើឯកសារនេះផ្ញើទៅឲ្យអ្នកណា? អ្នកណាជាអ្នកទទួលឯកសារនេះ? និងជាពិសេសប្រតិចារឹកនៅក្នុងបញ្ជី

ឯកសាររបស់ ខៀវ សំផន។ សូមផ្តល់កាលបរិច្ឆេទនៃព្រឹត្តិការណ៍នីមួយៗផង និងបើមេធាវីការពារក្តី ខៀវ សំផន ត្រូវលើកឯកសារណាមកសួរ។ ហើយជាពិសេសសូមផ្តល់ទីតាំងផង ភូមិ ឃុំ ស្រុក ឬក៏តំបន់ ឬក៏ភូមិភាគ ហើយក៏សូមផ្តល់ ឲ្យផ្តល់អំពីអត្តសញ្ញាណរបស់អ្នកដែលផ្តល់ព័ត៌មាន ថាតើជាប្រជាជនសាមញ្ញ ជាចាម ជាវៀតណាម ជាកម្មាភិបាលខ្មែរក្រហម ឬក៏ជាអ្នកណា?

ហើយយើងខ្ញុំស្នើសុំយ៉ាងដូច្នេះ ដោយសារថាអ្នកជំនាញ គាត់បានលើកឡើងពីម្សិលមិញថាពិបាកសម្រាប់គាត់ក្នុងការផ្តល់ជាគំនិតយោបល់ ពាក់ព័ន្ធទៅនឹងឯកសារណាមួយក្រៅពីការប្រព្រឹត្តមកលើជនជាតិចាម និងជនជាតិវៀតណាម។ អ៊ីចឹងគាត់ស្នើសុំថា ឲ្យផ្តល់កាលបរិច្ឆេទហ្នឹង ផ្តល់នូវទីតាំងភូមិសាស្ត្រ កាលបរិច្ឆេទ។ ខ្ញុំយល់ឃើញថា មេធាវីការពារក្តីប្រហែលជានឹងធ្វើបែបនេះហើយ។

កាលដែលខ្ញុំលើកនេះ គឺដោយសារថាអ្នកជំនាញពិបាកនឹងផ្តល់មតិយោបល់ទៅលើឯកសារថ្មីៗ បើសិនណាជាមិនផ្តល់ខ្លឹមសារទៅគាត់នោះទេ។ ដូច្នេះជាចុងក្រោយ ខ្ញុំមិនដឹងថាវាមានសារៈប្រយោជន៍ទៅដល់អ្នកជំនាញប៉ុនណានោះទេ។ ប៉ុន្តែពាក់ព័ន្ធទៅនឹងបណ្តាឯកសារដែលមេធាវីការពារក្តី ខៀវ សំផន ដែលអាចផ្តល់ជូនពាក់ព័ន្ធទៅនឹងទីតាំងភូមិសាស្ត្រ ហើយខ្ញុំមិនមានផែនទីរបស់ ប៉ែន យៀវនិន ទេ គឺឯកសារ E3/1593, ERN អង់គ្លេស 01149979។ នេះគឺជាអត្ថបទចម្លងនៃផែនទីរបស់គាត់ ស្តីអំពីតំបន់ ហើយនិងភូមិភាគនៃកម្ពុជាប្រជាធិបតេយ្យ ដើម្បីបង្កលក្ខណៈឲ្យអ្នកជំនាញអាចនឹងលើកយកមកសំអាងបាន។ ដូច្នេះការធ្វើបែបនេះ ធ្វើឲ្យគាត់ងាយក្នុងការឆ្លើយតបទៅបានរលូន។

ខ្ញុំសូមសួរទៅលោកប្រធាន ថាតើអត្ថបទថតចម្លងនៃផែនទីនេះ តើអាចជូនទៅអ្នកជំនាញបានឬក៏អត់?

[០៩:១៦:៤១]

**កញ្ញា អង់តា ហ្គីសសេះ**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខ្ញុំមានការកត់សម្គាល់មួយចំនួន។ ជាដំបូង គឺទៅលើសំណើរបស់សហព្រះរាជអាជ្ញាគឺ E390។ ខ្ញុំបានផ្ញើអ៊ីម៉ែលរួចទៅហើយ ដើម្បីឲ្យភាគីអាចដឹងអំពីសំណើរបស់ខ្ញុំ ដើម្បីឲ្យមានការឆ្លើយតបបានងាយស្រួលនៅក្នុងសវនាការ។ ក៏ប៉ុន្តែដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងកាលពីម្សិលមិញ យើងបានទទួលនូវម៉ែលមួយ ដែលមានការស្នើសុំឲ្យកោះហៅសាក្សីថ្មីទៅលើវគ្គសវនាការដែលកំពុងប្រព្រឹត្តទៅនេះ។ ហើយខ្ញុំឮភាគីម្ខាងទៀតបានបញ្ជាក់ថា ត្រូវទៅឲ្យលឿន ពន្លឿននីតិវិធី។ អ៊ីចឹងហើយបានជាខ្ញុំសុំទៅដល់ថ្ងៃចន្ទ ព្រឹក។

ធម្មតាយើងមានពេល១០ថ្ងៃ ដើម្បីឆ្លើយតប ហើយប៉ុន្តែនេះ ខ្ញុំមិនឆ្លើយ ខ្ញុំមិនសុំពេលយូរពេលប៉ុន្មានទេ សុំតែត្រឹមពេលព្រឹកថ្ងៃចន្ទតែប៉ុណ្ណោះ។ ខ្ញុំឮខាងសហព្រះរាជអាជ្ញាគាត់ត្រូវធ្វើម៉េចឲ្យដំណើរការនីតិវិធីហ្នឹងឲ្យលឿន។ ដូច្នេះខ្ញុំនៅតែរក្សាសំណើរបស់ខ្ញុំដដែល គឺថាធ្វើម៉េចទុកពេលឲ្យខ្ញុំ ដើម្បីឲ្យខ្ញុំឆ្លើយតបឲ្យបានពេញលេញ ដើម្បីផលប្រយោជន៍នៃនីតិវិធី។ បើអ៊ីចឹងបើចង់បានចម្លើយ ត្រូវតែធ្វើម៉េចទុកពេលឲ្យខ្ញុំផង។ អ៊ីចឹងដល់ចន្ទព្រឹកហ្នឹង គឺវាមិនយូរអីទេ។ អ៊ីចឹងហើយយើងឃើញថា យើងខ្ញុំកំពុងតែសួរអ្នកជំនាញ។ អ៊ីចឹងខ្ញុំសុំតែពេលប៉ុន្មានម៉ោងតែប៉ុណ្ណោះ ដើម្បីពិនិត្យមើលសំណើនេះ ហើយនៅក្នុងនោះមានបង្ហាញឯកសារមួយចំនួនផងដែរ។

[០៩:១៨:៣៤]

អ៊ីចឹងខ្ញុំចង់ពិនិត្យមើលឡើងវិញ ឲ្យល្អ ដើម្បីឆ្លើយតប។ ដូច្នេះយើងនៅតែរក្សាទុកដដែល នៃសំណើរបស់យើង គឺសុំធ្វើការឆ្លើយតបនៅថ្ងៃចន្ទព្រឹក។ ហើយចំពោះភាពឆាប់រហ័សនៃនីតិវិធីនោះ គឺយើងដឹងហើយថា វាមានការស្នើសុំដើម្បីកោះហៅសាក្សីថ្មី ដើម្បីជំនួសសាក្សីមួយចំនួនដែលស្លាប់ទៅ។ ដូច្នេះប្រសិនបើសហព្រះរាជអាជ្ញាព្រួយបារម្ភ ចង់ឲ្យនីតិវិធីឲ្យបានលឿននោះ គាត់គួរតែដាក់សំណើតាំងពីមុន។ មិនត្រូវទើបតែមកដល់ថ្ងៃនេះ ប៉ុន្មានថ្ងៃចុងក្រោយនេះ ទើបបានដាក់សំណើ ហើយឲ្យយើងឆ្លើយឲ្យលឿនទេ។ អ៊ីចឹង បើគាត់ -- បើយើងគិតទៅលើបញ្ហាឆាប់រហ័សនៃនីតិវិធីហ្នឹង ក៏យើងត្រូវតែគិតទៅលើសមភាពមធ្យោបាយតទល់ក្តីដែរ។ សហព្រះរាជអាជ្ញាមកសវនាការនេះ គាត់មិនមែនជាអ្នកធ្វើសំណើទេ ព្រោះគាត់មានគ្នាច្រើន ហើយយើង យើងមានគ្នាតិច។ យើងមកសវនាការផង យើងត្រូវពិនិត្យមើលសំណើផ្សេងៗផង ហើយឆ្លើយតបផង។ អ៊ីចឹង វាមិនមានសមភាពគ្នាទេ។ ដូច្នេះខ្ញុំគិតថា ថ្ងៃចន្ទព្រឹកហ្នឹង វាសមស្របហើយ ហើយវាមិនមែនជាពេលវេលាអីដែលថា ចម្លែកអស្ចារ្យអីដែលយើងត្រូវការទេ គឺវាសមស្របតែប៉ុណ្ណោះ។ នេះគឺធ្វើយ៉ាងម៉េច ដើម្បីឲ្យយើងអាចឆ្លើយតបទៅនឹងសំណើ E390 បាន។

ចំពោះលក្ខខណ្ឌថ្មី ដែលសហព្រះរាជអាជ្ញាចង់ស្នើឡើងនោះ ពាក់ព័ន្ធទៅនឹងការសំណួររបស់ខ្ញុំទៅកាន់អ្នកជំនាញនោះ វាមានហើយគឺឯកសារមួយចំនួនដែលយើងចង់ដាក់បង្ហាញជូនអ្នកជំនាញនោះ។ ហើយខ្ញុំ ៗភ្ញាក់ផ្អើលណាស់ចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញានោះ ព្រោះថាពេលដែលគាត់សួរនោះ ខ្ញុំមិនមានការតវ៉ាអីទេ ខ្ញុំអត់មានបានលើកឡើងនូវការព្រួយបារម្ភរបស់ខ្ញុំទេ ហើយខ្ញុំ ៗផ្តល់ឯកសារមិនច្រើនអីប៉ុន្មានទេ។ ហើយកាលពីម្សិលមិញ នៅពេលដែលមេធាវីការពារក្តីលោក នួន

ជា បានបង្ហាញឯកសារមួយចំនួននោះ ពួកគាត់បានផ្ដល់ការពន្យល់ ហើយពេលនុ៎ងគេស្ដីឲ្យសហព្រះរាជអាជ្ញា ស្ដីឲ្យថា មិនគួរណាពន្យល់ ហើយធ្វើដូចជាខ្លួនឯងមេធាវីជាអ្នកផ្ដល់សក្ខីកម្មអីអ៊ីចឹងទេ។ ដល់ពេលឥឡូវគាត់មកថា បើឲ្យយើងខ្ញុំដាក់ឯកសារ គួរតែខ្ញុំពន្យល់បរិបទសិនអីអ៊ីចឹង។ គាត់ដូចជាមើលទៅដូចជាម្ដងអ៊ីចេះម្ដងអ៊ីចុះ។

ខ្ញុំៗព្យាយាមធ្វើយ៉ាងម៉េចឲ្យបានឆាប់រហ័ស ធ្វើយ៉ាងម៉េចឲ្យមានការយល់ដឹង ហើយធ្វើម៉េចកុំឲ្យមានការភាគីផ្សេងទៀតជំទាស់។ ហើយបើខ្ញុំធ្វើការបង្ហាញនោះវាមិនសមស្របនោះ គឺត្រូវឲ្យបញ្ជាក់ឲ្យបានច្បាស់។ អ៊ីចឹងដូចខ្ញុំប្រាប់ពីម្សិលមិញទៅអ្នកជំនាញអ៊ីចឹង ថាបើសិនបើខ្ញុំការបង្ហាញខ្ញុំទៅមានភាពលម្អៀង អ៊ីចឹងសហព្រះរាជអាជ្ញាងើបឡើងជំទាស់ទៅ។ អ៊ីចឹងខ្ញុំសូមបន្តការសួរសំណួរដោយធ្វើតាមវិធីសាស្ត្ររបស់ខ្ញុំដដែល។ ហើយខ្ញុំព្យាយាមធ្វើម៉េចសង្ខេបឲ្យបានខ្លី ដើម្បីឲ្យវាឆាប់ចប់ ឲ្យវាស្របទៅតាមពេលវេលាដែលអង្គជំនុំជម្រះកំណត់បាន។ អ៊ីចឹងគាត់មិនគួរណាមកដាក់លក្ខខណ្ឌឲ្យយើងថាយើងត្រូវធ្វើអ៊ីចេះធ្វើអ៊ីចុះ បន្ទោសយើងថាយើងមិនបានធ្វើអ៊ីចេះមិនបានធ្វើអ៊ីចុះ។ ពេលភាគីផ្សេងធ្វើគាត់តែងតែជំទាស់អ៊ីចេះ ហើយអ្នកផ្សេងធ្វើមួយទៀត គាត់ជំទាស់របៀបមួយផ្សេង។ អ៊ីចឹងវា យើងពិបាកធ្វើការណាស់។ ខ្ញុំៗធ្វើយ៉ាងម៉េច គឺថាធ្វើយ៉ាងម៉េចបង្ហាញបរិបទឲ្យបានច្បាស់ ដកស្រង់ឯកសារមក ព្យាយាមសង្ខេប និយាយយ៉ាងម៉េចឲ្យបានលឿន សួរ ហើយខ្ញុំក៏ខ្ញុំបានផ្ដល់ឯកសារសំខាន់ៗទៅឲ្យលោកអ្នកជំនាញហ្នឹងរួចទៅហើយ ដើម្បីឲ្យគាត់បានពិនិត្យមើលជាមុននោះ។

[០៩:២២:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវអង្គជំនុំជម្រះសម្រេចដូច្នេះ ទី១ គឺលើបញ្ហានៃសំណើសុំរបស់សហព្រះរាជអាជ្ញាស្នើសុំស្ដាប់សក្ខីកម្មសាក្សីបន្ថែមជំនួសអ្នកដែលទទួលមរណភាពទៅនោះ អង្គជំនុំនឹងពិនិត្យពិចារណា ហើយជម្រាបជូនភាគីនៅក្រោយពេលសម្រាកនេះ។ ហើយបញ្ហាទី២ គឺកិច្ចដំណើរការគឺប្រព្រឹត្តទៅតាមធម្មតា ហើយប្រសិនបើមានបញ្ហាអីប្រឈមខ្លាំង ភាគីដែលពាក់ព័ន្ធដទៃទៀត ដែលជាភាគីម្ខាងទៀតនុ៎ង គឺអាចជំទាស់តវ៉ាបាន ដូចអ្វីដែលយើងបានធ្វើមក។ ហើយទី៣ គឺមេធាវីការពារក្ដី ខៀវ សំផន មិនគប្បីកាត់ការឆ្លើយតបរបស់អ្នកជំនាញទេ ព្រោះចំណេះដឹង វាមានវិសាលភាពធំធេង ស៊ីជម្រៅលើបញ្ហា។ អ៊ីចឹងក្នុងនាមឋានៈអ្នកជំនាញ ក្នុងនាមជានរវិទូមួយរូប មិនអាចឆ្លើយសាមញ្ញដូចជាសាក្សីសាមញ្ញៗមកចំពោះមុខអង្គជំនុំជម្រះបានទេ។ អង្គជំនុំជម្រះក៏ចង់ស្ដាប់នូវការអត្ថាធិប្បាយរៀបរាប់

ក្បោះក្បាយ ស៊ីជម្រៅតាមស្ថានភាពនៃភាពជំនាញរបស់គាត់ ដែលគាត់អាចផ្តល់សក្ខីកម្មចំពោះអង្គជំនុំជម្រះបានដែរ។ ហើយបញ្ហាចុងក្រោយ គឺអង្គជំនុំជម្រះអនុញ្ញាតឲ្យផ្តល់នូវឯកសារមួយ ដែលជាផែនទី ៗ សម័យកម្ពុជាប្រជាធិបតេយ្យ ដែលសហព្រះរាជអាជ្ញារងអន្តរជាតិបានបង្ហាញអំមិញ ទទួលយកឯកសារនោះទៅជូនអ្នកជំនាញពិនិត្យទៅ វាមិនមានបញ្ហាអីទេ ព្រោះឯកសារនេះនៅជាឯកសារនៅក្នុងសំណុំរឿងស្រាប់ហើយ ហើយយើងបានសួរដេញដោលច្រើនលើកហើយ។

មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារនោះទៅជូនអ្នកជំនាញ ហើយអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន បន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

[០៩:២៤:៣៧]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន តើខ្ញុំសូមឯកសារនេះបានទេ សហព្រះរាជអាជ្ញាសុំឲ្យ -- លោកប្រធានសុំឲ្យសហព្រះរាជអាជ្ញាបញ្ជូនឯកសារហ្នឹងឲ្យខ្ញុំផង ដើម្បីឲ្យយើងមានអាចពិនិត្យមើលឯកសារនេះបានផង លោកប្រធាន។

**លោក វីល្លៀម ស្មីត៖**

ខ្ញុំមានប្រហែលជា១០ច្បាប់ឯណោះលោកប្រធាន អាចចែកជូនទៅបាន។ នេះគឺជាឯកសារផែនទីថតចម្លងចេញពីសៀវភៅរបស់ ប៉ែន យៀរនិន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំទទួលបានមួយច្បាប់ហើយ សូមអរគុណ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ហ៊ីនតុន។ សូមអភ័យទោសដែលមានការជជែកពិភាក្សាគ្នា ធ្វើឲ្យពន្យារការសួរសំណួរលោក។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកតទៅទៀត ខ្ញុំយោងទៅលើឯកសារមួយនៅក្នុងដុំ បាក់ៗ ឯកសារហ្នឹងដែលដាក់លេខរៀងប្រាំ ដែលជាអត្ថបទ ស្ទីវ ហេដឌ័រ ខ្ញុំដឹងថាលោកប្រហែលជាស្គាល់អត្ថបទហ្នឹងហើយ ពីព្រោះថា ខ្ញុំឃើញមានដាក់នៅក្នុងគន្ថនិទ្ទេសនៃសៀវភៅរបស់លោកដែរ លោកយើងទៅលើអត្ថបទហ្នឹងដែរ។ អត្ថបទហ្នឹងគឺរិះគន់ទៅលើសៀវភៅរបស់ ប៉ែន យៀរនិន គឺឯកសារE3/3995។ ខ្ញុំចាប់អារម្មណ៍ទៅលើឃ្លាមួយដែលនៅ ERN ជាភាសាបារាំង 00802832

ជាភាសាអង់គ្លេស ខ្ញុំគិតថា ខ្ញុំដាក់*ផុសអ៊ីត* នៅលើកន្លែងហ្នឹងហើយ លោកអាចមើលបានគឺ ERN ជាភាសាអង់គ្លេស 00773767 ទៅដល់68, ERN ជាភាសាខ្មែរ 00844612 ទៅដល់14។ ប៉ុន្តែអ្វីដែលខ្ញុំចាប់អារម្មណ៍សំខាន់នោះគឺនៅ ERN 00844612 ជាភាសាខ្មែរ។

[០៩:២៧:០០]

កន្លែងនោះ ស្ទីវ ហេដឌ័រ គាត់លើកឡើងអំពីសញ្ញាណមួយគឺសញ្ញាណនៃ "ក្បាលយួន ខ្លួនខ្មែរ។ ខ្ញុំចង់ឲ្យលោកពន្យល់ទៅលើឃ្លាមួយនេះ គឺកថាខណ្ឌទី២ ជាភាសាបារាំង។ ខ្ញុំសូមដកស្រង់នូវអ្វីដែល ហេដឌ័រ គាត់បានបកស្រាយ នៅក្នុងការបង្ហាញទស្សនៈរបស់ខ្លួន គាត់បានលើកឡើងអំពីជនរងគ្រោះជាច្រើននៅភូមិភាគបូព៌ាដែលគេចាត់ទុកថាជា "ក្បាលយួន ខ្លួនខ្មែរ"។ ពាក្យនេះមានន័យថា ជាអ្នកដែលមានខ្លួនខ្មែរ ហើយមានខួរក្បាលយួន ហើយអ្នកហ្នឹងហើយដែលជាអ្នកដែលត្រូវគេសម្លាប់ចោល។ ពាក្យនេះក៏ត្រូវបានប្រើប្រាស់កាលពីមុនមកផងដែរ ដើម្បីបង្ហាញអំពីរូបភាពមួយនៃរចនាសម្ព័ន្ធនយោបាយខ្មែរក្រោមការគ្រប់គ្រងរបស់វៀតណាម។

ទទ្ធីករណ៍របស់ ឃៀរនិន ដែលថាពាក្យនេះត្រូវបានប្រើប្រាស់ដើម្បីលុបបំបាត់ប្រជាជនភាគច្រើនខ្មែរ ដោយសារតែមូលហេតុពូជសាសន៍ ដែលថាពួកគេមិនមែនជាខ្មែរសុទ្ធ ហើយនៅក្នុងនោះវាមានជាករណីស្មុគស្មាញ។ ពាក្យនេះ គឺមានន័យថាជាការតម្រង់ទិសនយោបាយ ដើម្បីកំណត់តាមលក្ខណៈមនោគមន៍វិជ្ជា។ អ្នកដែលជាខ្មែរនោះ មិនមានការការពារអ្វីឲ្យបានច្បាស់លាស់ទេ ហើយការក្បត់វណ្ណៈ និងក្បត់បុព្វហេតុជាតិហ្នឹង គឺជាហេតុផលនយោបាយ។ ដូច្នេះអ្នកណាដែលជាអ្នកជំទាស់ទៅនឹងគោលនយោបាយរបស់គេនោះ គឺគេត្រូវតែកម្ទេចចោល ទោះបីជាមានពណ៌សម្បុរ ឬក៏សក់ ឬក៏អីយ៉ាងម៉េចក៏ដោយ គឺគេមិនទុកទេ។

ដូច្នេះខ្ញុំចង់បានទស្សនៈរបស់លោកខាងផ្នែកនរវិទ្ធូ ផ្នែកនរវិទ្យា ថាតើលោកយល់យ៉ាងណាចំពោះការលើកឡើងរបស់លោក ស្ទីវ ហេដឌ័រ នេះ ដែលគាត់ជាអ្នកនិពន្ធមួយរូបដ៏ល្បីល្បាញនៅក្នុងក្របខ័ណ្ឌនៃការងាររបស់គាត់ស្តីអំពីកម្ពុជាប្រជាធិតេយ្យនោះ?

[០៩:២៨:៤២]

**លោក អាឡិចសាន់ឌឺ ហ៊ីនតុន៖**

**ឆ៖** សូមអរគុណ។ ខ្ញុំក៏សូមបន្ថែមផងដែរ យើងក៏មានបញ្ហាបកប្រែពីម្សិលមិញ។ ខ្ញុំសូមបញ្ជាក់ថា សូមបញ្ជាក់មេធាវីការពារក្តីម្សិលមិញគឺថា បកទៅជាភាសាបារាំងថា*ម៉ាដាម*។ អ៊ីចឹងទេថា

តើខ្ញុំហៅយ៉ាងដូចេ្នះបានទេ លោកស្រី?

**ស៖** លោក ហ៊ីនតុន លោកចង់ហៅខ្ញុំស្ទីក៏បានដែរ មេធាវីក៏បាន លោកស្រីក៏បាន អត់បញ្ហាអីទេលោក។

**ឆ៖** ឯកសារនេះជាឯកសារសំខាន់ណាស់ មានសារៈសំខាន់ណាស់ពី ស្ទីវ ហេនឌ័រ ក៏ដូចជា ប៉ែន យៀវនិន ដែលជាការចូលរួមចំណែកមួយ ហើយពួកគាត់មានការយល់ស្របទៅលើចំណុចមួយចំនួន ក៏ដូចជាចំណុចខុសគ្នាមួយចំនួន ហើយពួកគាត់ក៏បានបកស្រាយនូវព្រឹត្តិការណ៍។ ក្នុងនោះគាត់និយាយអំពីលទ្ធិម៉ាក្ស-ឡេនីន។ ហើយ ស្ទីវ ហេដឌ័រ លើកឡើងអំពីការសម្លាប់មនុស្ស ហើយ ប៉ែន យៀវនិន គាត់ពិនិត្យសំខាន់ជាងគេទៅលើការរើសអើង។ ខ្ញុំមិនចង់កាត់បន្ថយនូវការកត់សម្គាល់របស់គាត់យ៉ាងណានោះទេ ប៉ុន្តែអត្ថបទរបស់ ស្ទីវ ហេដឌ័រ ហាក់បីដូចជាចង់បង្ហាញថា គឺនិយាយអំពី -- គាត់ភាគច្រើននិយាយអំពីចេតនា ៗដែលនាំឲ្យមានការប្រព្រឹត្តអំពើសម្លាប់រង្គាល គឺថាដែលចេតនានេះគឺមានជាយូរយារណាស់មកហើយ ដើម្បីចង់សម្លាប់ក្រុមជាក់លាក់ណាមួយ។ ពីព្រោះថានេះគឺជាដំណើរការពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ។ ទទ្ទឹករណ៍របស់ ស្ទីវ ហេដឌ័រ គឺថាគាត់ផ្តោត ប្រៀបធៀបទៅនឹងលទ្ធិ ទៅនឹងម៉ាក្ស-ឡេនីនច្រើន។

[០៩:៣១:៥៣]

ដូចដែលខ្ញុំបានលើកឡើងហើយ គោលបំណងក្នុងការអប់រំកែប្រែមនសិការរបស់មនុស្សមួយចំនួនដែលបន្តធ្វើរហូតមកដល់ឆ្នាំ១៩៧៦ ទើបចាប់ផ្តើមមានការបោសសម្អាត។ ការដែលឲ្យប្រជាជនទៅកាន់ទីជនបទនេះ គឺដើម្បីឲ្យគាត់មានលះបង់ ហើយនិងសម្រួចមនសិការបដិវត្តន៍។ អ៊ីចឹងពីឆ្នាំ៧៦ ទៅដល់៧៧ ស្ថានភាពវាមានការកែប្រែ គឺវាមានការអនុវត្តទៅតាមមូលដ្ឋាននីមួយៗ ដូចខ្ញុំបានជម្រាបពីខាងដើម ថាការបកស្រាយរបស់ខ្ញុំដែលក្នុងការវាយប្រហារទៅលើវៀតណាមនេះ គឺវាជាប់ពាក់ព័ន្ធទៅនឹងការរើសអើង។ ឯចំពោះជនជាតិចាមវិញ គឺថាមានដំណើរការវែងឆ្ងាយ ហើយក្រោយពេលពួកគាត់ងើបបះបោរ ពួកគាត់ក៏ត្រូវការបំបែកចេញពីគ្នា ហើយក៏ត្រូវបានគេកំណត់ជាគោលដៅ។

នេះគឺជាផ្នែកមួយនៃសៀវភៅការពិភាក្សារបស់ ស្ទីវ ហេដឌ័រ ពាក់ព័ន្ធទៅនឹងភូមិភាគ ការសម្លាប់រង្គាលនៅភូមិភាគបូព៌ា។ ហើយខ្ញុំគិតថា ប៉ែន យៀវនិន ក៏យល់ស្របទៅនឹងចំណុចរបស់ ស្ទីវ ហេដឌ័រ ពាក់ព័ន្ធទៅនឹងពាក្យ "ឃ្លួន" ដែលគេត្រូវបានយកមកប្រើប្រាស់ទៅតាមមធ្យោបាយ និងបរិបទផ្សេងៗ។

ដូចខ្ញុំលើកឡើងពីខាងដើមរួចមកហើយ ប៉ែន យៀវនិន គឺថា គាត់មិនបានបង្ហាញថា គាត់មានការជំទាស់ទាំងស្រុងនោះទេ ក៏ប៉ុន្តែគាត់មានការជំទាស់តិចតួច។ អ៊ីចឹងមុនយើងឈានទៅដល់ការសន្និដ្ឋាននោះ ត្រូវពិនិត្យមើលឯកសាររបស់ ស្ទីវ ហេដឌ័រ។ ពាក់ព័ន្ធទៅនឹងការបោសសម្អាតនៅឯភូមិភាគបូព៌ា ខ្ញុំថាជាអំពើប្រល័យពូជសាសន៍ ខ្ញុំអាចលើកជាទឡ្ហីករណ៍បាន។

[០៩:៣៣:៥៦]

**ស៖** សូមអភ័យទោសលោកប្រធាន ដែលខ្ញុំត្រូវកាត់ផ្តាច់។ លោកប្រធានប្រាប់ខ្ញុំហើយថាកុំឲ្យកាត់ផ្តាច់ ក៏ប៉ុន្តែប្រហែលជាសំណួរខ្ញុំមិនច្បាស់ ឬក៏យ៉ាងម៉េច ខ្ញុំចង់បញ្ជាក់សំណួរខ្ញុំឡើងវិញ ដើម្បីឲ្យអ្នកជំនាញគាត់ឆ្លើយបន្តទៅទៀត។ លោក ៗនិយាយអំពីពាក្យ "យួន" ...។ល។ សំណួរខ្ញុំគឺខ្ញុំផ្តោតទៅលើពាក្យមួយ គឺសំនួនវោហារស័ព្ទមួយដែលមានន័យថា "ក្បាលយួនខ្លួនខ្មែរ"។ ហើយខ្ញុំចង់ដឹងថា តើការពន្យល់របស់ យៀវនិន នោះ ហើយយ៉ាងម៉េច? ហើយចំពោះលោកនោះ តាមលក្ខណៈនរវិទ្យាហ្នឹង តើលោកយល់យ៉ាងម៉េចចំពោះពាក្យហ្នឹង? ខ្ញុំផ្តោតទៅលើពាក្យហ្នឹងទេ "ក្បាលយួន ខ្លួនខ្មែរ" ហ្នឹងចង់ឲ្យលោកអត្ថាធិប្បាយទៅលើពាក្យហ្នឹង។

**ឆ៖** សូមអរគុណលោកស្រីមេធាវី។ ដូចខ្ញុំបានលើកឡើងពីខាងដើមហើយ ពិបាកណាស់អត្ថបទនេះ ជាអត្ថបទមួយដែលវាពិបាក។ អ៊ីចឹងវាពិបាកសម្រាប់ខ្ញុំក្នុងការផ្តល់ចម្លើយខ្លី ដែលត្រឹមថា "បាទ" ឬក៏ "ទេ"។ ដោយសារខាងម៉ាក្ស-ឡេនីន ហ្នឹងក៏មានការប្រើប្រាស់នូវសក្តានុពលឲ្យបែបនេះផងដែរ។ ហើយចំពោះឃ្លានេះ ដែលប្រើពាក្យ "យួន" ត្រូវបានគេប្រើប្រាស់ទៅតាមមធ្យោបាយផ្សេងៗអាស្រ័យទៅលើបរិបទ ក៏ដូចជា ការញុះញង់ដែលកើតមានឡើងនៅពេលនោះ។ ដូច្នេះយើងត្រូវតែមើលទៅតាមបរិបទរបស់វា។

**ស៖** ចំណុចមួយទៀតដែលខ្ញុំចង់ពិភាក្សាជាមួយលោក ហើយវាពាក់ព័ន្ធទៅនឹងសញ្ញាណមួយនេះ ដែលវាមានលក្ខណៈប្រែប្រួលទៅតាមពេលវេលា ហើយនៅពេលដែលយើងពិនិត្យមើលឯកសារណាមួយ វាអាចមានន័យផ្សេង។ ដូច្នេះក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវរបស់លោក ខ្ញុំចង់ដឹងថាតើលោកមានធ្វើការស្រាវជ្រាវជាក់លាក់អ្វីទៅលើជម្លោះព្រំដែន ឬក៏វាជាចំណុចបន្ទាប់បន្សំទេ នៅក្នុងការស្រាវជ្រាវរបស់លោក?

[០៩:៣៦:២០]

**ឆ៖** សូមអរគុណលោកស្រីមេធាវី។ ដូចជាខ្ញុំបានលើកឡើងអ៊ីចឹង គឺថាការផ្តោតរបស់ខ្ញុំទៅ

លើសៀវភៅនេះ គឺថាវាមានភាពលើសលុបទៅលើប្រជាជនដែលរស់នៅភូមិពោធិ៍ ស្រុកកំពង់សៀម ប៉ុន្តែក្នុងឋានៈជា ក្នុងនាមជាទស្សនវិទូ គឺថាខ្ញុំត្រូវកម្រិតមើល នៅក្នុងកម្រិតមូលដ្ឋានទៅតាមបរិបទរបស់វាដែលខ្ញុំធ្វើការសិក្សាស្រាវជ្រាវជាបឋមកាលនោះ។ ក៏ប៉ុន្តែខ្ញុំបានយោងទៅលើប្រភពឯកសារបន្ទាប់បន្សំផងដែរ យ៉ាងដូច្នេះមែនបាទ។

**ស៖** ខ្ញុំយល់។ ខ្ញុំដឹងថា លោកបានពិគ្រោះឯកសារមួយចំនួននៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងបរិបទជាក់លាក់មួយ ហើយវាមិនដូចនឹងអ្វីដែលបានរៀបចំនៅថ្ងៃនេះទេ។ ខ្ញុំយល់ពីការពន្យល់របស់លោកកាលពីម្សិលមិញ។ ដូច្នេះខ្ញុំចង់ដឹងថា ជាអាទិ៍នោះ គឺវាពាក់ព័ន្ធទៅនឹងការប្រជុំរបស់គណៈអចិន្ត្រៃយ៍។ អ៊ីចឹងខ្ញុំចង់ពិនិត្យមើលជាមួយលោក គឺនៅឯកសារលេខ២ នៅក្នុងដុំរបស់ខ្ញុំឱ្យលោកនុ៎ង គឺឯកសារ E3/221។ ខ្ញុំចង់ដឹងថា លោកមានបានពិគ្រោះកំណត់ហេតុគណៈអចិន្ត្រៃយ៍ហ្នឹងដែរឬទេ? គឺចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៤ លោកមានបានពិគ្រោះទេ នៅពេលដែលលោកធ្វើការស្រាវជ្រាវកាលពីមុននោះ ឬក៏លោកទើបតែដឹងនៅពេលក្រោយមកនេះទេ?

**ឆ៖** សូមអរគុណលោកស្រី។ ពិបាកចាំបន្តិច ប៉ុន្តែខ្ញុំមិនជឿជាក់ថា ខ្ញុំមិនធ្លាប់បានឃើញឯកសារនេះទេ ដោយសារថាមានឯកសារច្រើនណាស់ ហើយឆ្នាំនោះក៏វាយូរឆ្នាំណាស់មកហើយដែរ។ អ៊ីចឹងខ្ញុំមិនប្រាកដថា ខ្ញុំចងចាំទេ។

[០៩:៣៨:២៣]

**ស៖** ខ្ញុំយល់ថា ដោយសារតែឯកសារច្រើន។ អ៊ីចឹងលោកមិនអាចមើលបានគ្រប់ឯកសារទេ។ អ៊ីចឹងមិនមានបញ្ហាអ្វីទេលោក។ សំណួរជាទូទៅ នៅក្នុងក្របខ័ណ្ឌនៃជម្លោះព្រំដែនរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម នៅពេលដែលលោកធ្វើការស្រាវជ្រាវ ឬក៏លោកអានប្រភពបន្ទាប់បន្សំផ្សេងៗ តើលោកមានបានដឹងអំពីបញ្ហាបន្ទាត់ប្រេវីយ៉េ ឬក៏បញ្ហាដែលកើតឡើងជុំវិញបន្ទាត់ប្រេវីយ៉េនេះ? លោកមានបានពិភាក្សា សិក្សាទៅលើបញ្ហាហ្នឹងទេ? លោកមានអ្វីត្រូវជម្រាបជូនទេត្រង់ចំណុចនេះ?

**ឆ៖** តាមការសិក្សាស្រាវជ្រាវជាទូទៅរបស់ខ្ញុំ ជាពិសេសនៅក្នុងគម្រោងជាក់លាក់មួយនេះ គឺខ្ញុំមាននិយាយនៅក្នុងសៀវភៅរបស់ខ្ញុំ។

**ស៖** ខ្ញុំចង់ពិនិត្យមើលជាមួយលោកនៅឃ្លាមួយចំនួននៅក្នុងឯកសារមួយនេះ ដែលផ្ទុយទៅនឹងកំណត់ហេតុផ្សេងទៀតរបស់គណៈអចិន្ត្រៃយ៍ ដែលក្នុងនេះ គឺនិយាយអំពីការសង្កេតទៅលើបញ្ហាមួយដែលខ្ញុំបានលើកឡើងហ្នឹង។ ឯកសារហ្នឹងមានចំណងជើងថា “ពិនិត្យអំពីប្រតិកម្មវៀតណាម” ក្នុងអង្គ

ប្រជុំលើកទី៥ ព្រឹកថ្ងៃទី១៤ ឧសភា ៧៦។ អ៊ីចឹងក្នុងនេះ មានការចរចាគ្នាជាមួយវៀតណាមទៅលើបញ្ហាព្រំដែន។

[០៩:៤០:០៨]

នៅERN00386178, ជាហើយជាភាសាខ្មែរគឺ 00000813 និងជាភាសាអង់គ្លេសគឺ 00182695 បន្តទៅដល់96 គឺបទអន្តរាគមន៍របស់សមមិត្ត ខៀវ ដែលជាឈ្មោះបដិវត្តន៍របស់ សុន សេន។ គាត់ជាតំណាងឲ្យកងកម្លាំងប្រដាប់អាវុធ។ នេះជាសម្ដីរបស់គាត់ គឺគាត់និយាយសំដៅទៅលើវៀតណាម៖ “នៅព្រំដែន វាចេះតែចូលជាប់ អត់មានឈប់ទេ។ យើងអត់ទៅរករឿងហេតុវាសោះ តាមពិសោធន៍ បើវាចូលមក យើងមិនដេញ វាមិនទៅទេ។ ដល់តែយើងតឹងដាក់វាវិញ ទើបវាចេញទៅ។ នេះនៅខាងរតនគិរី។” ខ្ញុំសូមអានជាភាសាបារាំង៖ “ឯខាងមណ្ឌលគិរី យើងអត់វ៉ៃវាសោះ គឺយើងគោរពតាមការណែនាំរបស់បក្សដាច់ខាតមិនឲ្យតឹងតែង។ បន្ទាប់មកទៀតសមមិត្តលេខាដែលជា ប៉ុល ពត បានសួរបញ្ជាក់ តាមការពិភាក្សានេះ តើវាចង់ពន្យាពេលមិនទាន់ចង់ផ្ដាច់ ឬយ៉ាងណា? នេះទី១។ ទី២ ជាមតិវាតាមការណែនាំរបស់បក្សវា តែវាមករៀបរៀង ឬយ៉ាងម៉េច? ទី៣ វាស្ទិតទៅទៀតដើម្បីស្ទង់មើលក្រែងយើងមានប្រែប្រួល។ ទី៤ មានភេទអីដែលគួរឲ្យយើងចាប់អារម្មណ៍ក្នុងការចរចា។”

នៅក្នុងឃ្លាទាំងនេះ មូលហេតុដែលខ្ញុំសូមឲ្យលោកមានប្រតិកម្មតបហ្នឹង គឺថាខ្ញុំចង់ដឹងថាតើនៅក្នុងក្របខ័ណ្ឌនៃការសិក្សាទៅបរិបទទូទៅនោះ លោកមាននឹកឃើញទេ ថានៅខែឧសភា ឆ្នាំ៧៦ មានការពិភាក្សាគ្នាជាមួយវៀតណាមអំពីបញ្ហាព្រំដែន? ហើយតើលោកមានធ្វើការប្រៀបធៀបអ្វីទេនៅពេលដែលលោកធ្វើការសិក្សាស្រាវជ្រាវនៅតំបន់៤១នោះ? គឺលោកមានមើលឃើញថាមានអ្វីដែលកើតឡើងពិតប្រាកដនៅខែឧសភា ឆ្នាំ៧៦ ហើយនិងការបន្តការចរចាគ្នារវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមនោះ?

[០៩:៤៣:១៥]

**ឆ៖** សូមអរគុណលោកស្រីមេធាវី។ ជាថ្មីម្តងទៀត ការព្រួយបារម្ភរបស់ខ្ញុំ គឺពិភាក្សាទៅលើបទពិសោធន៍ប្រជាជនមកពីភូមិពោធិ៍។ កាលដែលខ្ញុំលើកយ៉ាងដូច្នេះ ដោយខ្ញុំធ្លាប់អានកិច្ចការរបស់ណាយ៉ាន់ ចាន់ដា, ដេវីដ ឆេនដ៍ល័រ និយាយអំពីបញ្ហាហ្នឹង គឺថារុញទៅរុញមក រុញទៅរុញមកជាមួយគ្នា ហើយក៏មានការចរចារវាងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម។ តើគោលបំណងហ្នឹងចង់បានយ៉ាងម៉េចដែរ ដោយសារថាមានការបាញ់បោះគ្នាចាប់តាំងពីឆ្នាំ៧៥ រហូតទៅដល់៧៧, ៧៨ ក៏

កាន់តែកើនខ្លាំងឡើងៗ។ ហើយនៅក្នុងឆ្នាំ៧៦ របបកម្ពុជាប្រជាធិបតេយ្យព្យាយាមកំណត់នូវយុទ្ធ-សាស្ត្រណាមួយពាក់ព័ន្ធទៅនឹងភាពតានតឹងជាមួយវៀតណាម។

**ស៖** អ៊ីចឹងពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ខ្ញុំហ្នឹង គឺថាក្រៅពីបរិបទទូទៅនេះ តើលោកមានធ្វើការបែងចែកភាពខុសគ្នារវាងភ័ស្តុតាង ដែលលោកបានជាបន្តបន្ទាប់ចន្លោះពីឆ្នាំ៧៦, ៧៧, ៧៨ នៅតំបន់៤១នោះ តើលោកមានបានឃើញភាពខុសគ្នាទេ រវាងព័ត៌មានដែលលោកបានស្តាប់ឮពីអ្នកដែលលោកសម្ភាសនោះ?

**ឆ៖** សូមអរគុណលោកស្រីមេធាវី។ ខ្ញុំមិនច្បាស់ថា ការបកប្រែវាពិតប្រាកដយ៉ាងណាពាក់ព័ន្ធទៅនឹងធាតុផ្សេងៗនោះ។

[០៩:៤៥:១៨]

**ស៖** ប្រហែលជាខ្ញុំសួរមិនច្បាស់ អ៊ីចឹងខ្ញុំសួរឡើងវិញ។ លោកថា លោកបានកត់សម្គាល់ថា មានការចរចាគ្នា ហើយមានការវាយគ្នា វ៉ៃបណ្តើរចរចាបណ្តើរ ហើយមានភាពតានតឹងកាន់តែកើនឡើង។ អ៊ីចឹងខ្ញុំដឹងថា ពេលដែលលោកស្រាវជ្រាវនៅក្នុងតំបន់៤១នោះ ទោះបីជាលោកបញ្ជាក់ថា មានជនជាតិវៀតណាមតិចតួចបំផុតនៅតំបន់នោះក៏ដោយនោះ តើពេលដែលលោកស្រាវជ្រាវនោះភ័ស្តុតាងឬក៏ព័ត៌មានដែលលោកទទួលបានពីអ្នកដែលលោកសម្ភាសនោះ តើវាមានភាពខុសគ្នារវាងអង្គហេតុដែលកើតឡើងពិតប្រាកដនោះ នៅពេលដែលមានការចរចាគ្នានៅសម័យនោះ ហើយមានជម្លោះប្រដាប់អាវុធគ្នានោះ តើវាមានការភាពស៊ីសង្វាក់គ្នាទេ?

**ឆ៖** សូមអរគុណលោកស្រី។ ខ្ញុំនឹងផ្តោតទៅលើបរិបទដែលខ្ញុំសរសេរនៅក្នុងសៀវភៅថា ហេតុបានជាគេសម្លាប់មនុស្ស។ នេះគឺជាអ្វីដែលប្រជាជនបានរៀបរាប់អំពីបទពិសោធន៍របស់គាត់។ ដូចដែលខ្ញុំជម្រាបអ៊ីចឹង គឺថាការនិយាយអំពីកាលប្រវត្តិព្រឹត្តិការណ៍ពី៧៥ ដល់៧៦ ហើយព្រឹត្តិការណ៍នេះ ក៏ចេះតែបន្តមានពីឆ្នាំ៧៦ ទៅឆ្នាំ៧៧ទៀត។ បើនិយាយឲ្យទូលំទូលាយ គឺនៅពេលដែលគេចាប់រៀបបោសសម្អាត ចាប់រៀបយកមក ស-២១ ហើយដាក់ឈ្មោះ ផល ជំនួស ហើយនិងនៅពេលដែលគេយកមនុស្សពីភូមិភាគបូព៌ាយកមកសម្លាប់ចោល។ នេះគឺជាបរិបទប្រវត្តិសាស្ត្រដ៏ទូលំទូលាយ។ គឺអ្នកដែលត្រូវគេបានជ្រើសរើសចេញពីភូមិនេះតែម្តង។

**ស៖** ពាក់ព័ន្ធទៅនឹងការវិវឌ្ឍជាលក្ខណៈប្រវត្តិសាស្ត្រ និងជម្លោះជាមួយវៀតណាមនេះ ខ្ញុំចង់ត្រឡប់មកនិយាយឯកសារមួយដែលលោកបានផ្តល់យោបល់ជូនសហព្រះរាជអាជ្ញាគឺឯកសារ E3/460

4 គឺលេខកូដទី៣ នៅក្នុងបាច់ឯកសាររបស់ខ្ញុំ គឺសុន្ទរកថារបស់ ប៉ុល ពត ខែមេសា ឆ្នាំ៧៨។ លោកដឹងហើយថា ពេលដែលសហព្រះរាជអាជ្ញាសួរសំណួរហ្នឹង ខ្ញុំបានជំទាស់។ គឺដោយសារតែពេលនុ៎ង វាមានបញ្ហាបរិបទ ហើយពេលនោះលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញារួចហើយ ក៏ប៉ុន្តែខ្ញុំចង់ត្រឡប់មកឃ្លាមួយនៅក្នុងសុន្ទរកថានេះ ជាពិសេសគឺឃ្លាដែលនៅមុនឃ្លាដែលសហព្រះរាជអាជ្ញាបានដកស្រង់ ដើម្បីបង្ហាញបរិបទឲ្យបានច្បាស់លាស់។

[០៩:៤៨:២៣]

ឃ្លាដំបូងដែលខ្ញុំចាប់អារម្មណ៍នោះ គឺកាលបរិច្ឆេទនៃសុន្ទរកថាដែលមាននៅក្នុងទស្សនាវដ្ដីទង់បដិវត្ត ខែមេសា ឆ្នាំ៧៨នោះមានសារៈសំខាន់ណាស់ ពីព្រោះថាពេលនោះ យើងកំពុងតែមានជម្លោះជាមួយវៀតណាម។ ជាពិសេសជម្លោះនោះ គឺមានភាពតានតឹងមែនទែន។ ខ្ញុំសូមយោងទៅលើ ERN ជាភាសាអង់គ្លេស គឺទំព័រទី៥។ ERN 00519832, ERN ជាភាសាខ្មែរគឺ 00064711, ERN ជាភាសាបារាំងគឺ 00520342។ ខ្ញុំសូមអានឃ្លាមួយដើម្បីបង្ហាញបរិបទឲ្យបានច្បាស់។ ជាភាសាបារាំងគឺកថាខណ្ឌមុនចុងក្រោយនៃទំព័រនោះ។ ខ្ញុំសូមដកស្រង់៖ "សរុបទៅ ថ្ងៃ០៦ មករា ឆ្នាំ៧៨ យើងបានកម្ទេចកម្លាំងយួនឈ្លានពានឲ្យចេញពីទឹកដីយើងអស់រលីង។ កម្ទេចកម្លាំងរស់វាទាំងស្លាប់ ទាំងរបួស គឺ ២៩.០០០នាក់។ ធ្វើឲ្យកងពលវាប្រាំកងពលត្រូវបាត់។ ត្រូវបាក់ មានន័យថាខ្ទេច ប្រើមិនកើត ត្រូវរៀបចំឡើងវិញ។ នេះជាជ័យជម្នះរបស់យើងលើកទី១ វគ្គទី១ធំ។ ក្នុងពេលដែលយើងវាយខ្មាំងដណ្ដើមជ័យជម្នះវគ្គទី១នេះ ពេលនេះយើងមិនទាន់រៀបចំកម្លាំងយើងបានស្រួលបួលនៅឡើយដែរ។ កម្លាំងនៅក្នុងភូមិភាគនីមួយៗ ក៏ដូចជាកម្លាំងរបស់កងទ័ពមជ្ឈិមបក្ស ក៏មិនទាន់រៀបចំបានប្រុងប្រៀបវាយធំយ៉ាងនេះដែរ។ ទាំងចំនួនមនុស្ស ទាំងអាវុធ ក៏មិនទាន់រៀបចំបានខ្លាំងក្លាមែនទែន។ ប៉ុន្តែយើងវាយកម្ទេចវាឲ្យវាដកថយពីព្រំដែនយើងបាននៅថ្ងៃ០៦ ខែមករា ឆ្នាំ១៩៧៨ ដែលវាចាញ់វគ្គទី១។ វាត្រូវវាយយើងម្ដងទៀតវគ្គទី២។" សូមបញ្ចប់ការដកស្រង់។

សំណួរទី១ ពាក់ព័ន្ធទៅនឹងឯកសារនេះ នៅខែមករា ឆ្នាំ៧៨នេះ តើលោកមាននឹកឃើញអ្វីពាក់ព័ន្ធទៅនឹងការវាយប្រយុទ្ធគ្នា? អ៊ីចឹងបើយើងមើលទៅ ថាទៅចុង៧៧ ហើយនិងដើមឆ្នាំ៧៨នេះ លោកមាននឹកឃើញអំពីការវាយប្រយុទ្ធគ្នារវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមទេ?

[០៩:៥១:៣២]

**ឆ៖** សូមអរគុណលោកស្រី។ ខ្ញុំមើលទៅលើទង់បដិវត្ត ៧៨ ខ្ញុំមិនដឹងថាមើលទង់បដិវត្តឆ្នាំ

៧៨ ត្រឹមត្រូវឬក៏អត់ ទាក់ទងទៅនឹងកាលបរិច្ឆេទនេះ។ ខ្ញុំគិតថាមានបញ្ហាពីរ។ ទី១ ថាតើខ្ញុំផ្តោតទៅលើឯកសារនេះ ដែលខ្ញុំបានសរសេរនៅក្នុងសៀវភៅរបស់ខ្ញុំ។ ខ្ញុំនឹងពិនិត្យមើលឯកសារយោង ក៏ប៉ុន្តែ យ៉ាងណាក៏ដោយ ខ្ញុំបានដឹងអំពីឯកសារនេះ នៅពេលដែលមានការប្រកាសធ្វើសង្គ្រាមរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងវៀតណាម គឺថាច្បាស់ណាស់ថា សុន សេន បានទៅព្រំដែន ដើម្បីបញ្ជាការប្រយុទ្ធ។ ប៉ុន្តែជាទូទៅ លោកស្រីត្រូវមើលទៅលើឯកសារនេះទាំងស្រុងតែម្តង មិនត្រូវមើលតែមួយចំណែកណាមួយនៃឯកសារនោះទេ។ ដោយសារមួយផ្នែកធំ គឺវាពាក់ព័ន្ធទៅនឹងការប្រយុទ្ធជាមួយនឹងយួន។ ហើយគេប្រើពាក្យ “យួន” នេះដូចខ្ញុំបានលើកឡើងខាងដើម គឺថាវាបង្ហាញនូវចំណុចមួយចំនួនដែលជាការញុះញង់ និងជាទូទៅ។ ហើយក៏វាឆ្លុះបញ្ចាំងចំពោះជនជាតិវៀតណាមភាគតិចរស់នៅក្នុងប្រទេសកម្ពុជាផងដែរ។ គឺថាមានការនិយាយថា គឺសូម្បីតែមួយគ្រាប់ក៏មិនទុកឲ្យសល់ដែរ ដូចដែលសហព្រះរាជអាជ្ញារងអន្តរជាតិបានលើកឡើងអ៊ីចឹងដែរ ពិតណាស់គឺវានាំឲ្យទៅ ពាក្យនេះក៏វានាំឲ្យឈានទៅដល់ការប្រយុទ្ធយោធាទ្រង់ទ្រាយធំ ហើយពាក្យ “យួន” នៅពេលប្រយុទ្ធនេះ គឺសំដៅទៅលើប្រទេសវៀតណាម ហើយក៏វាឆ្លុះបញ្ចាំងចំពោះជនជាតិវៀតណាមភាគតិចរស់នៅក្នុងប្រទេសកម្ពុជាផងដែរ។

[០៩:៥៣:៣៨]

អ៊ីចឹងបើយើងមើលការវាយប្រយុទ្ធមួយចំនួនទៀត មានការញុះញង់។ របាយការណ៍របស់ ណាយ៉ាន់ ចាន់ដា នៅខែសីហា នៅពេលដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យប្រព្រឹត្តនូវអំពើហិង្សាមួយចំនួន ណាយ៉ាន់ ចាន់ដា គាត់ថា គាត់មានការភ្ញាក់ផ្អើលមែនទែន រន្ធត់មែនទែននៅពេលដែលឃើញការប្រព្រឹត្តពីសំណាក់កងទ័ពកម្ពុជាប្រជាធិបតេយ្យ។ នេះហើយគឺជាសក្តានុពលនៃការញុះញង់។ ខ្ញុំយល់ឃើញថាមានទាំងក្នុងឯកសារនេះ ក៏ដូចឯកសារដទៃទៀត។ ហើយដូចដែលខ្ញុំបានលើកឡើង គឺថាពាក់ព័ន្ធទៅនឹងស្ថានការណ៍យោធានេះ គឺយើងត្រូវមើលឯកសារទាំងស្រុង ថាតើវាឆ្លុះបញ្ចាំងទៅលើការវាយប្រយុទ្ធគ្នាសំដៅប្រទេសវៀតណាម ឬជនជាតិភាគតិចវៀតណាមនៅកម្ពុជា។

**សៈ** ខ្ញុំយល់អំពីការបកស្រាយរបស់លោក។ អ៊ីចឹងលោកថា វាមានផលប៉ះពាល់ទៅលើវៀតណាមដែលជាដើមកំណើតសុទ្ធវៀតណាម។ ហើយខ្ញុំ ៗបានដកស្រង់នូវឃ្លានៅក្នុងឯកសារហ្នឹងច្បាស់ណាស់។ ក្នុងនេះគេនិយាយអំពីការវាយប្រយុទ្ធគ្នានៅចុងឆ្នាំ៧៧ ដើមឆ្នាំ៧៨។ នេះជាការលើកឡើងរបស់ ប៉ុល ពត ដែលនិយាយអំពីជ័យជម្នះរបស់កម្ពុជាប្រជាធិបតេយ្យ។ ពាក្យដែលប្រើនៅក្នុងឯកសារ

ហ្នឹង ដែលខ្ញុំដកស្រង់ឲ្យលោកហ្នឹង គឺមាននិយាយអំពីកងពល យុទ្ធជន។ ដូច្នេះគឺសំដៅទៅលើយោធាហើយក្នុងនេះ។ អ៊ីចឹងលោកៗនិយាយថាមានការចង់វាយប្រហារទៅលើវៀតណាម ប្រជាជនដែលមានដើមកំណើតវៀតណាម ជនស៊ីវិល ក៏ប៉ុន្តែក្នុងនេះយើងមើលឃើញនិយាយអំពីយោធា។ តាមទស្សនៈនរវិទូ នៅពេលដែលយើងមើលទៅលើឯកសារមួយនេះ ខ្ញុំសូមរំឭកថា នេះជាសុន្ទរកថា ដែលបានថ្លែងនៅពេលដែលគេធ្វើបុណ្យជ័យជម្នះ ដែលនិយាយអំពីជ័យជម្នះរបស់កងទ័ពនេះ។ អ៊ីចឹងតាមរយៈការស្រាវជ្រាវរបស់លោកនោះ លោកថាមានការអំពាវនាវឲ្យការកម្ទេចជនជាតិវៀតណាមហ្នឹង តែក្នុងនេះយើងមើលឃើញ គឺគេសំដៅទៅលើតែកងទ័ពទេ។

[០៩:៥៦:០៧]

**ឆ៖** សូមអរគុណលោកស្រី។ សូមនិយាយឡើងវិញ ដូចខ្ញុំបានលើកឡើងខាងដើម គឺលោកស្រីត្រូវតែយកចិត្តទុកដាក់ ពិនិត្យទៅឯកសារនេះទាំងមូលតែម្តង ដើម្បីឲ្យយល់អំពីបរិបទរបស់វា។ ខ្ញុំមិនដឹងថា លោកស្រីសួរចំណុចដែលខ្ញុំដាក់*ហាយឡាយ*ជាពណ៌លឿងនេះទេ។ ចំណុចសំខាន់គឺមើលទៅលើភាពតានតឹង រវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យជាមួយវៀតណាម។ ដូចខ្ញុំបានលើកឡើងពាក្យ "យួន" នេះ នៅពេលដែលគេប្រើពាក្យ "យួន" គឺថាវាបង្ហាញនូវចំណុចពីរ។ ទី១ អាចយោងទៅលើ សំដៅទៅលើកងទ័ពវៀតណាម ហើយវាក៏ជាការកក្កូរកកាយញុះញង់ទៅដល់ជនជាតិវៀតណាមភាគតិចដែលជាពាក្យមួយ ជាពាក្យរើសអើងយ៉ាងខ្លាំងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

ដូច្នេះពាក្យ "យួន" ដែលប្រើប្រាស់នេះ គឺថាវាជាតំណាងទៅឲ្យអត្ថន័យច្រើនណាស់ មិនដឹងថាតើវាមានន័យតែមួយ សំដៅទៅលើចំណុចណាមួយ ឬក៏វាជាការញុះញង់ឲ្យមានកំហឹងចំពោះប្រទេសវៀតណាមតែម្តង ឬក៏ចំពោះកងទ័ពវៀតណាម។ អ៊ីចឹងវាមានន័យមិនច្បាស់ទេ អាចមានន័យទាំងពីរនេះឯង។ ដូចជាមានពាក្យនិយាយថា "ពួកវា សូម្បីតែពួកយួននេះ សូម្បីតែមួយគ្រាប់មិនសល់ផងនៅក្នុងប្រទេសកម្ពុជា"។ អ៊ីចឹងនេះបើយើងពិនិត្យមើលទៅលើកត្តាទីតាំងភូមិសាស្ត្រក៏យ៉ាងដូច្នេះដែរ។

[០៩:៥៨:០៥]

**ស៖** សំណួរមួយ នៅពេលដែលមានពាក្យមួយ ដែលអាចមានន័យផ្សេងនៅក្នុងបរិបទផ្សេងនេះ ប្រសិនបើយើងនៅក្នុងបរិបទមួយ ដូចជា តាមដែលខ្ញុំយល់នៅពេល តាមការអានរបស់ខ្ញុំ គឺខ្ញុំយល់ផ្សេង ក៏ប៉ុន្តែបើក្នុងបរិបទមួយផ្សេង ពាក្យហ្នឹងមានន័យផ្សេងមួយទៀត។ អ៊ីចឹងដូចជាក្នុងនេះ យើងនិយាយអំពីកងពល និយាយពីសមរភូមិ និយាយអំពីយុទ្ធជន និយាយពីកម្លាំងប្រដាប់អាវុធ អ៊ីចឹងក្នុង

បរិបទបែបហ្នឹង គឺវាមិនមានន័យដែលលោកនិយាយហ្នឹងទេ គឺព្រោះហ្នឹង ក្នុងហ្នឹងយើងមានន័យនិយាយកងទ័ពវាបង្ហាញច្បាស់។ បើក្នុងបរិបទផ្សេងពាក្យ “យួន” ហ្នឹងអាចវាមានន័យផ្សេង ខ្ញុំយល់ ក៏ប៉ុន្តែក្នុងកន្លែងនេះ គឺពាក្យ “យួន” ហ្នឹងគឺមើលទៅយើងសំដៅទៅលើយោធាហើយ មិននិយាយអំពីជនស៊ីវិលទេ ពីព្រោះយើងឃើញមានពាក្យ “ការវាយប្រយុទ្ធ សមរភូមិ កងពល” អ៊ីចឹងម៉េចក៏បានលោកប៉ាននិយាយថា ពាក្យ “យួន” ហ្នឹងក៏គេនិយាយអំពីប្រជាជនស៊ីវិលដែរ បើក្នុងហ្នឹងយើងឃើញថាមានពាក្យ សុទ្ធតែជាពាក្យកងទ័ពនោះ?

**ឆ៖** សូមអរគុណលោកស្រី។ វាងាយស្រួលទេ ខ្ញុំអាចលើកឧទាហរណ៍ក្រោយពីព្រឹត្តិការណ៍ថ្ងៃ១១ ខែកញ្ញា នៅសហរដ្ឋអាមេរិក នៅសហរដ្ឋអាមេរិកគេចាប់ផ្ដើមវាយប្រហារទៅលើប្រជាជនដែលគេយល់ឃើញថាជាមូស្លីម ឬក៏ជនជាតិអារ៉ាប់។ ការប្រើពាក្យហ្នឹង គឺសំដៅទៅលើភេរវករនៅមជ្ឈឹមបូព៌ា។ អ៊ីចឹងនៅពេលដែលយើងប្រើពាក្យ “រើសអើង” ដែលនាំឱ្យមានការបញ្ឆេះទៅដល់សាធារណជន ក៏គេសំដៅទៅលើកងទ័ពដែរ។ លោកស្រីត្រឹមត្រូវហើយ លោកស្រីលើកនោះ ក៏ប៉ុន្តែវាក៏បង្កឱ្យមានកំហឹងចំពោះជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជាផងដែរ។

ខ្ញុំសូម -- មេធាវីការពារក្ដី នួន ជា ក៏បានលើកឡើងមកទាក់ទងទៅនឹងអំឡុងពេលនៅក្នុងសម័យអ៊ុនតាក់នោះ ក៏គេមានប្រើពាក្យនេះដែរ។ អ៊ីចឹងកាលណា ការញុះញង់តាមរយៈការប្រើភាសានេះ គឺវាពេលខ្លះវាសំដៅទៅលើកងទ័ព ប៉ុន្តែវាមិនសំដៅទៅលើប្រជាជនទាំងមូលនោះទេ។ ដូចខ្ញុំនិយាយថា ជាពាក្យៗ អង់គ្លេសថា “*ម៉ាកឃីង ឌិហ្វេរិន*” អីគេនេះ គឺជាការ*(ឮមិនច្បាស់)* វាបង្ហាញឱ្យឃើញការកំណត់ចំកន្លែងណាមួយឱ្យបានច្បាស់លាស់។ តើជាការកំណត់ចំយួន ឬក៏អត់? ដូចខ្ញុំបញ្ជាក់អ៊ីចឹង “យួន” នេះគេប្រើគឺពាក់ព័ន្ធទាំងទៅលើយោធា ហើយក៏ជាការបញ្ឆេះកំហឹង គេសំដៅទៅលើជនជាតិភាគតិចវៀតណាមរស់នៅក្នុងប្រទេសកម្ពុជានាសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។

[១០:០១:២៣]

**ស៖** ចំពោះបញ្ហាដែលលោកបានផ្ដល់យោបល់ជាមួយសហព្រះរាជអាជ្ញា ខ្ញុំក៏ចង់បានមតិពីលោកដែរ ពាក់ព័ន្ធទៅនឹងការរ៉ៃមួយទល់នឹង៣០នាក់នោះ។ ក្នុងនេះមានសម្ដីរបស់ ប៉ុល ពត ដែលគាត់និយាយអំពីភាពបែកខ្ញែក ឬភាពខុសគ្នារវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរ។ គឺទំព័រ៦ ជាភាសាអង់គ្លេស លោកមានឯកសារហ្នឹងក្នុងដៃហើយ 00519834 ជាភាសាអង់គ្លេស, ជាភាសាខ្មែរគឺ 0006 4714, ជាភាសាបារាំងគឺ 00520345។ នេះជាឃ្លាមួយទៀតនៃឯកសារនេះ ខ្ញុំសូមដកស្រង់៖ “តើ

យើងអនុវត្តមាគ៌ាសង្គ្រាមយ៉ាងម៉េចដើម្បីឈ្នះ ខ្ញុំសូមជម្រាបថា សរុបទៅរហូតដល់ថ្ងៃនេះ មួយទល់នឹង ៣០ គឺយើងសម្រេចបានហើយ។ នៅសមរភូមិស្វាយរៀង យើងសរុបលទ្ធផលនៅក្នុងខែ៣ នៅស្វាយរៀង មួយទល់នឹង៩០ឯណោះ។ កម្ពុជាមួយ យួនត្រូវខ្មោច៩០។ ប៉ុន្តែមានសមរភូមិដទៃទៀតក៏ មួយទល់នឹងប្រាំ, មួយទល់នឹង១០, មួយទល់នឹង១៥, មួយទល់នឹង ២០។ អ៊ីចឹងសរុបទៅទូទាំងប្រទេស យើងសម្រេច មួយទល់នឹង៣០បាន។ ដូច្នេះយួនវាខ្មោចខ្ចីកម្លាំងច្រើន។ កម្លាំងវាច្រើនមែន ប៉ុន្តែវាត្រូវខ្មោចខ្ចីច្រើន។ យ៉ាងម៉េចបានជាវាត្រូវខ្មោចខ្ចីច្រើន? វាមានកម្លាំងច្រើន មានកាំភ្លើងធំ មានរថក្រោះច្រើនជាងយើងនោះ។ ខ្ញុំសូមជម្រាបថា កាំភ្លើងធំនិងរថក្រោះរបស់វាច្រើនជាងយើង ប៉ុន្តែកាំភ្លើងថ្មើរជើងវាមិនមែនឈ្នះយើងទេ។ ថ្មើរជើងយ៉ាងម៉េចបានជាយើងវាយឈ្នះ? ខ្ញុំសូមជម្រាបពីយោធាបន្តិច ដើម្បីឲ្យយល់ ឃើញថាយើងអនុវត្ត មួយទល់នឹង៣០បាន យើងមិនវាយដោយប្រមូលផ្តុំកម្លាំងទេ កងពលរបស់យើងចែកជាច្រើនផ្នែក។" សូមបញ្ចប់ការដកស្រង់។

[១០:០៥:៤១]

ដូច្នេះយើងនិយាយអំពីខ្មែរមួយ ទល់នឹងយួន៣០នាក់។ ដូច្នេះទោះបីជាពាក្យប្រើយ៉ាងម៉េចក៏ដោយនៅក្នុងនេះ គឺយើងសំដៅទៅលើការវាយប្រយុទ្ធគ្នានៅសមរភូមិ។ យើងមានចំនួនខុសគ្នារវាងចំនួនកងទ័ពខ្មែរ និងកងទ័ពវៀតណាម។ អ៊ីចឹងហើយពេលហ្នឹងបានជាគេលើកឡើងអំពីបញ្ហាមួយ ទល់នឹង៣០នាក់នោះ។ ដូច្នេះខ្ញុំចង់សួរលោកបញ្ជាក់ថាក្នុងនេះ មួយទល់នឹង៣០នេះ លោកមើលឃើញយ៉ាងម៉េច បានជាថានិយាយតែទៅលើជនស៊ីវិលដែរនោះ?

**ឆ៖** សូមអរគុណមេធាវីការពារក្តី។ ខ្ញុំមិនដឹងដែរពាក់ព័ន្ធជាមួយនឹងការបកប្រែ ក៏ដូចជាពាក់ព័ន្ធទៅនឹងកថាខណ្ឌ ក៏ដូចជាពាក់ព័ន្ធនឹងទីតាំងហ្នឹង ថាសូមបញ្ជាក់ឲ្យច្បាស់បន្តិចមកពាក់ព័ន្ធនឹងឯកសារជាភាសាអង់គ្លេសកន្លែងណាមួយ។ គាត់សូមមើលជាភាសាអង់គ្លេសសិន។

**ស៖** អម្បាញ់មិញនេះខ្ញុំប្រាប់លោកទៅហើយ អង់គ្លេសហ្នឹងគឺភាសា គឺទំព័រ៦ ហើយលេខ ERN គេដាក់នៅខាងឆ្វេងគឺ 00519834។ អ៊ីចឹងលោកសូមមើលនៅខាងឆ្វេងឯកសារហ្នឹង ខាងឆ្វេងដៃលោកឃើញមានដាក់លេខ ERN។

**ឆ៖** អូខេ! អ៊ីចឹងលោកស្រីអានផ្នែកខាងលើផ្នែកខាងក្រោម ហើយអ្វីដែលសំខាន់ យើងចង់ដឹងឲ្យមើលថាតើវាអានជាភាសាអ្វីដើម្បីយើងដឹងឲ្យច្បាស់។

**ស៖** សូមអភ័យទោស ខ្ញុំបារាំង ខ្ញុំមិនដឹងថាតើអង់គ្លេសនៅលើដើមទំព័រ ឬក៏ចុងទំព័រទេ

ពីព្រោះខ្ញុំអានជាភាសាបារាំង ខ្ញុំមើលតែអត្ថបទជាភាសាបារាំង ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក្នុងនេះ គេនិយាយអំពីសមរភូមិនៅស្វាយរៀង។ គេថានៅសមរភូមិស្វាយរៀង យើងសរុបលទ្ធផលនៅខែ៣ ក្នុងនោះថាខ្មែរមួយទល់នឹងយួន៣០នាក់ ហើយនិយាយអំពីរថក្រោះ និយាយពីកាំភ្លើងធំ។ អ៊ីចឹងលោកមើលពិនិត្យមើលទៅ អ៊ីចឹងបើលោកចង់ពិនិត្យមើលឯកសារយ៉ាងម៉េច លោកប្រាប់ខ្ញុំមកដើម្បីថាលោកសុំពេលដើម្បីអានឯកសារហ្នឹង ប្រាប់ខ្ញុំទៅ។

[១០:០៧:១៣]

**ឆ៖** សូមអរគុណមេធាវីការពារក្តី។ ខ្ញុំចង់បញ្ជាក់នេះ ពីព្រោះថាពាក្យថា "យួន" ដែលឃើញនៅក្នុងអត្ថបទនេះ គឺយើងចង់ដឹងឲ្យច្បាស់នៅក្នុងប្រយោគនីមួយៗនេះ ដើម្បីយើងពិនិត្យទៅលើពាក្យដែលបញ្ជាក់ពីវៀតណាមនេះ គឺពេលខ្លះវាមានលក្ខណៈច្រឡំ។ អ៊ីចឹងយើងឃើញនៅក្នុងនេះ គឺមានពាក្យ "យួន" ហ្នឹងច្រើននៅលើអត្ថបទនេះ។

**ស៖** បើខ្ញុំភ្លេចរំឭកលោកជាមុន ជាភាសាអង់គ្លេសប្រហែលជាអាចមានពាក្យគេបកផ្សេងប្រហែលជាបកត្រូវ ហើយបារាំងជួនកាលក៏អាចបកខុស ហើយពេលខ្លះហ្នឹងនៅពេលដែលយើងបង្ហាញឯកសារហ្នឹង ក៏យើងបានលើកឡើងដែរថាមានបកការបកប្រែខុសអីអ៊ីចឹង។ ក៏ប៉ុន្តែទោះជាយ៉ាងណា នេះជាឯកសារផ្លូវការរបស់តុលាការដែលគេបកប្រែ យើងមិនអាចកែប្រែអីបានទេ ហើយប៉ុន្តែពាក្យអង់គ្លេស គឺបកត្រឹមត្រូវតែម្តងក្នុងនេះ គឺយួនហ្នឹង។

**ឆ៖** សូមអរគុណមេធាវីការពារក្តី។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ទៅលើចំណុចនេះ ពីព្រោះថាយើងឃើញថាមានការបកប្រែនេះវា យើងអាចភ័យខ្លាចក្រែងលវាដាក់ខុសលំដាប់លំដោយវា។ ហើយជាពិសេសយើងក៏ត្រូវចំណាយពេលត្រូវអានទៀត ព្រោះថាយើងមិនមានពេលច្រើន។ ដូចអ្វីដែលខ្ញុំឆ្លើយពីសំណួរពីមុនអ៊ីចឹង គឺខ្ញុំសូមបញ្ជាក់ម្តងទៀត បរិបទនេះគឺវា យើងឃើញហើយវាមានការពាក់ព័ន្ធគ្នា គឺបរិបទយោធា ក៏ដូចជាការប្រយុទ្ធគ្នាប្រឆាំងទៅនឹងប្រទេសវៀតណាម។ ហើយជាពិសេសហើយយើងឃើញថា ការកំណត់ប្រើប្រាស់ពាក្យនេះ គឺឃើញថានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនេះ គឺសំដៅលើជនជាតិវៀតណាម ឬក៏ប្រទេសវៀតណាម ឬក៏ជនជាតិវៀតណាមនៅក្នុងកម្ពុជា។

[១០:០៩:០៨]

ហើយបរិបទនេះ ដូចដែលខ្ញុំបញ្ជាក់ពីមុនហ្នឹង គឺពាក្យនេះគឺវាមានន័យផ្សេងៗ ក៏ដូចជាមានន័យជាទូទៅសំដៅលើជនជាតិវៀតណាមដែរ ដែលរស់នៅក្នុងប្រទេសកម្ពុជា។ ដូចដែលខ្ញុំបញ្ជាក់នៅក្នុង

ឧទាហរណ៍មួយ នៅក្នុងសហរដ្ឋអាមេរិក គឺវាមានជាតិសាសន៍ជាច្រើន ពាក្យដែលគេប្រើសំដៅទៅលើជាតិសាសន៍ណាមួយ ហើយគេប្រើពាក្យទាំងអស់នេះ គឺសំដៅទៅលើអ្នកណាមួយក្រុម ជាពិសេសគឺការកំណត់នេះ គឺវាអាចមានលក្ខណៈជាអវិជ្ជមាន ដូចជាមានពាក្យ “យួន” អីជាដើម ឬក៏ពាក្យ “យួន” ដែលបានប្រើម្តងហើយម្តងទៀតនោះ គឺខ្ញុំបានបញ្ជាក់ម្តងហើយម្តងទៀតដូច្នេះដែរ ប្រសិនបើចង់ឲ្យខ្ញុំបញ្ជាក់ទៀត ខ្ញុំរីករាយនឹងបញ្ជាក់ទៀត។

**ស៖** ដើម្បីឲ្យច្បាស់អំពីគំនិតរបស់លោក ចំពោះលោក ពាក្យថា “យួន”នេះទោះបីជាក្នុងបរិបទណាក៏ដោយ ទោះបីជាគេនិយាយច្បាស់អំពីការវាយប្រយុទ្ធ អំពីសមរភូមិ និយាយអំពីកាំភ្លើង អំពីរថ-ក្រោះ កាំភ្លើងធំអីក៏ដោយ គឺឲ្យតែប្រើពាក្យ “យួន” ចំពោះលោក គឺសំដៅជាទូទៅតែម្តងទៅលើប្រជាជនស៊ីវិល ទាំងទាហាន។ អ៊ីចឹងមានន័យថាអ៊ីចឹងមែនទេ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ គឺថាឲ្យតែប្រើពាក្យ “យួន” ហ្នឹង គឺសំដៅទៅលើយួន វៀតណាមជាទូទៅតែម្តង ទាំងស៊ីវិល ទាំងយោធា?

[១០:១០:៥០]

**ឆ៖** សូមអរគុណមេធាវីការពារក្តី។ ខ្ញុំចង់បញ្ជាក់ថា ទស្សនីករណ៍របស់ខ្ញុំហ្នឹង គឺថានៅពេលដែលយើងប្រើពាក្យដែលវាអាចប៉ះពាល់ ជាពិសេសពាក់ព័ន្ធនឹងករណីមួយចំនួន ដែលគេប្រើពាក្យហ្នឹង ទៅតាមស្ថានភាព។ ហើយពាក់ព័ន្ធទៅនឹងការប្រើប្រាស់ពាក្យក្តីហ្នឹង យើងអាចស្វែងយល់បានដែរ ឧទាហរណ៍ដូចជាពាក់ព័ន្ធនឹងពាក្យ “ជនជាតិចាម” អីជាដើមនោះ គឺយើងដឹងហើយ ការប្រើប្រាស់ពាក្យហ្នឹង គឺយើងដឹងច្បាស់ពាក់ព័ន្ធទៅនឹងប្រើពាក្យ “យួន”ហ្នឹង គឺវាមានបរិបទទូលំទូលាយ។ ជាពិសេសពាក់ព័ន្ធទៅនឹងជនជាតិភាគតិច គឺគេមានការសំដៅការញុះញង់ ឬក៏ស្អប់ខ្ពើមអីជាដើមនោះ គឺតាមរយៈអ្វីដែលបានបញ្ជាក់ហ្នឹង គឺវាមានបញ្ជាក់នៅក្នុងឯកសារនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ការផ្សព្វផ្សាយតាមវិទ្យុផ្សាយសំឡេងអីជាដើម។ គឺបើនិយាយអំពីកងទ័ពវៀតណាម-កម្ពុជា ហើយក៏មានការប្រយុទ្ធមួយចំនួនដែលកើតមានឡើង ដែលវាពាក់ព័ន្ធទៅនឹងអំពើហិង្សាប្រឆាំងទៅនឹងប្រជាជន គឺយើងឃើញថា ពាក្យហ្នឹងពេលខ្លះ គឺវាប្រើដែលមានន័យដូចគ្នាដែរ។ ហើយពាក្យ “យួន” ហ្នឹង ក៏អាចសំដៅទៅលើជនជាតិវៀតណាមជាទូទៅដែរ ដែលគេអាចបញ្ជាក់ថា ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមដែលរស់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះដែរ ឬក៏សំដៅទៅលើក្រុមជនជាតិវៀតណាមមួយក្រុមអីជាដើម។ ហើយជាពិសេសនៅក្នុងឆ្នាំ៧៨នោះ គឺមានពាក់ព័ន្ធនឹងក្រុមនេះ។ ហើយខ្ញុំយល់ថា គឺវាជាពាក្យដែលសំដៅទៅលើន័យទូទៅតែម្តង ដែលសម្រាប់ញុះញង់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ា ឡាវែន៍!

[១០:១២:៤៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរទៅកាន់មេធាវី ហ្គីសសេ តើលោកស្រីមានបានឃើញមានភាពខុសគ្នារវាងភាសាបារាំង និងភាសាអង់គ្លេសទេ? ហើយមានការធ្វើសំណើទៅអង្គភាពបកប្រែ ដើម្បីឲ្យធ្វើម៉េចឲ្យវាមានខ្លឹមសារដូចគ្នាទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

យើងបានកត់សម្គាល់ឃើញភាពខុសគ្នាហ្នឹង ហើយខ្ញុំដឹងថា អង្គជំនុំជម្រះក៏ឃើញដែរ។ អ៊ីចឹងប្រហែលជាខ្ញុំគិតថា អង្គជំនុំជម្រះប្រហែលជាបានធ្វើសំណើទៅអង្គភាព អាយ.ធី.យូ។ អ៊ីចឹងទោះជាយ៉ាងណាក៏ដោយ ក្នុងនេះគេក៏ប្រើពាក្យ "យួន" ចំពោះយើង គឺយើងអត់ទាន់បានធ្វើសំណើជាក់លាក់អ្វីទៅខាងអង្គភាពបកប្រែទេ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីជំនាញរូបនេះ នៅក្នុងអំឡុងឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី ហើយមុននឹងផ្តល់វេទិកាជូនទៅភាគីពាក់ព័ន្ធ អង្គជំនុំជម្រះសូមជម្រាបជូនថា អង្គជំនុំជម្រះបានសម្រេចថាសំណើរបស់សហព្រះរាជអាជ្ញា សុំស្នើសុំស្តាប់សក្ខីកម្មសាក្សីបន្ថែម ឬក៏សាក្សីជំនួស ដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុចោទប្រកាន់មន្ទីរមន្ទីរសន្តិសុខភ្នំក្រោល ឯកសារ E390នោះ អង្គជំនុំជម្រះសម្រេចថានឹងស្តាប់ភាគីនៅព្រឹកថ្ងៃច័ន្ទ សប្តាហ៍ក្រោយ។

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមអធ្យាស្រ័យដែលខ្ញុំកាត់ ខ្ញុំរំខាន។ ពេលវេលាតាំងសំណួររបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន។ ប៉ុន្តែខ្ញុំសូមលើកឡើងនូវសំណើមួយពាក់ព័ន្ធទៅនឹងអ្នកជំនាញ ដែលត្រូវបញ្ចប់ការផ្តល់សក្ខីកម្មនៅត្រឹមម៉ោងបាយថ្ងៃត្រង់នេះ។ សក្ខីកម្មរបស់គាត់ព្រឹកមិញនេះ ពាក់ព័ន្ធទៅនឹងការប្រើពាក្យថា "យួន" គឺថាកូនក្តីខ្ញុំគាត់មានការខកចិត្តណាស់ចំពោះសក្ខីកម្មក្នុងការបកស្រាយទៅលើការប្រើប្រាស់ថា "យួន" នេះ។ ហើយគាត់ស្នើសុំថា នៅពេលចាប់ផ្តើម ចាប់ផ្តើមនៅថ្ងៃរសៀលក្រោយពិសាបាយថ្ងៃត្រង់នេះ គឺគាត់ស្នើសុំ នួន ជា គាត់ស្នើសុំពេលវេលាពី៥ទៅ១០នាទីទេ ដើម្បីឆ្លើយតប មានប្រតិកម្មទៅនឹងការលើកឡើងអំពីពាក្យ "យួន" ពីសំណាក់លោកអ្នកជំនាញ ហ៊ីនតុន។

[១០:៣៦:១៦]

**កញ្ញា អង់តា ហ្គីសសេ៖**

មុននឹងអស់លោក លោកស្រីចៅក្រមធ្វើសេចក្តីសម្រេចនឹងបញ្ហានេះ ទាក់ទងនឹងពេលវេលាក្រុម ខៀវ សំផន យើងមានបីវគ្គនៅសល់ទៀត យើងខ្ញុំបានចាប់ផ្តើមកាលព្រឹកមិញប្រហែលម៉ោង០៩:២៥ហើយ អ៊ីចឹងខ្ញុំសួរថាតើរយៈពេល២៥នាទីនេះ ដែលយើងខាតនេះ អង្គជំនុំជម្រះសងយើងវិញទេ? ហើយបន្ទាប់មកទៀត លោកមេធាវី គង់ សំអុន ហ្នឹងក៏គាត់មានសំណួរត្រូវសួរផងដែរ។ អ៊ីចឹងខ្ញុំចង់សួរទៅអង្គជំនុំជម្រះ ថាតើគិតយ៉ាងម៉េចដែរ ចំពោះពេលវេលាពួកខ្ញុំនេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មឹត៖**

សូមអរគុណលោកប្រធាន។ ទាក់ទងទៅនឹងសំណើសុំរបស់មេធាវី នួន ជា គឺយើងខ្ញុំមិនជំទាស់ទេ។ ហើយតាម ថាតើលោកអ្នកជំនាញឆ្លើយតបទៅនឹងសំណើនេះ ឬក៏យ៉ាងនោះ។ នេះគឺវាអាស្រ័យទៅលើពេលវេលា។ សហព្រះរាជអាជ្ញា កាលពីសួរកាលថ្ងៃចន្ទ ក៏បាត់បង់ពេលវេលាយ៉ាងច្រើនដែរ ដោយមានការជំទាស់យ៉ាងច្រើន។ ដូច្នេះពាក់ព័ន្ធទៅនឹងគោលការណ៍សមភាពនៃគូក្តី គឺថាក្រុម ខៀវ សំផន ក៏បាត់បង់ពេលវេលាដូចតែយើងខ្ញុំដែរ។ ដូច្នេះតើមេធាវីការពារក្តីនេះអាចនឹងបញ្ចប់បានមុនពេលបន្តិចបានទេ ដោយសារថាខាងយើងខ្ញុំនេះក៏បាត់បង់ពេលវេលាច្រើន ដោយការជំទាស់ជាហូរហែនោះដែរ។

[១០:៣៨:០៧]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមើលទៅដូចថាមានការជំទាស់នៅពេលដែលលោកមេធាវី កូប៉េ សួរសំណួរផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវបន្តស្តាប់ទៅ ហើយអង្គជំនុំជម្រះមិនផ្តល់ឲ្យទេ អាចផ្តល់ឲ្យបន្តិចបន្តួចនៅពេលវេលាម៉ោងនេះ ដោយមូលហេតុថាប្រាំពីរវគ្គសវនាការសម្រាប់ភាគីនីមួយៗ អង្គជំនុំជម្រះបានប្រើប្រាស់ពេលវេលាស្មើរតែមួយវគ្គនៅក្នុងការតាំងសំណួរបឋមចំពោះអ្នកជំនាញ។ អ៊ីចឹងវាប៉ះពាល់ទៅលើការប្រើប្រាស់ពេលវេលារបស់ភាគីសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ។ បញ្ហាទី២ មានការជំទាស់តវ៉ាច្រើន វាប្រហាក់ប្រហែលគ្នាទេ វាអាចខាងសហព្រះរាជអាជ្ញាបានតាំងសំណួរកន្លងមានការចំណាយពេលវេលាច្រើន។ ដូច្នេះ ព្យាយាមប្រឹងប្រែងធ្វើយ៉ាងណាអនុវត្តឲ្យបានត្រឹមត្រូវទៅ ហើយបើសិនជាចង់បន្ថែម គឺព្រឹកម៉ោងពីរដណ្តប់ ម៉ោងមួយដណ្តប់កន្លះទៅពីរដណ្តប់ហ្នឹង ស្រេចតែលោកស្រីទេ ព្រោះបញ្ហានោះវាអាស្រ័យលើកូនក្តោរបស់លោកស្រី។

[១០:៣៩:១៧]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំបានកត់ត្រាទុកហើយលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក ហ៊ីនតុន ដើម្បីបញ្ចប់អំពីបញ្ហាសុន្ទរកថារបស់លោក ប៉ុល ពត ឆ្នាំ១៩៧៨ ខ្ញុំសូម

អានសម្រង់មួយទៀតពីចម្លើយរបស់សាក្សីម្នាក់ គឺសាក្សី ព្រុំ សារ៉ាត់ គឺឯកសារ E1/382.1 ថ្ងៃទី២៦ មករា ឆ្នាំ២០១៦ គឺក្រោយម៉ោង១៥:៣៦:៤២វិនាទី។ នេះដើម្បីផ្តល់បរិបទដល់លោក ហ៊ីនតុន។ លោក ព្រុំ សារ៉ាត់ គាត់ជាមេបញ្ជាការទាហាន ហើយក្រោយមកគាត់ក្លាយជាកាពីទែនទាហានជើងទឹក។ នៅពេលនោះសហព្រះរាជអាជ្ញាគាត់បានសុំឲ្យគាត់បញ្ចេញប្រតិកម្មទៅលើសុន្ទរកថា ប៉ុល ពត នេះដែរ។ អ៊ីចឹងខ្ញុំនឹងចោទសំណួរលោកហើយ អ៊ីចឹងកុំឲ្យមានបញ្ហាទាក់ទងនឹងបរិបទ កាលណោះសហចៅក្រមអន្តរជាតិគាត់សួរដូចតទៅនេះ៖ "ខ្ញុំដឹងថានៅក្នុងសុន្ទរកថានេះ គាត់បាននិយាយដូចតទៅនេះ ប៉ុល ពត និយាយថា បើប្រជាជនខ្មែរ២លាននាក់ហ្នឹង អាចឈ្នះប្រជាជនវៀតណាម៦០លាន។ ហើយអ៊ីចឹង តើលោកសាក្សី លោកមានឮ ប៉ុល ពត និយាយយ៉ាងដូច្នេះដែរឬទេ? អង្កាល់ណោះលោក ព្រុំ សារ៉ាត់ គាត់ឆ្លើយដូចតទៅនេះ៖ ការពិតវាជាការប្រៀបធៀបកម្លាំងយោធាមួយទល់នឹង៣០។"

ដូច្នេះក្នុងឯកសារនេះគឺបញ្ជាក់ច្បាស់ ខ្ញុំនៅតែចាប់យកថាជាឯកសារដែលលើកឡើងដោយកងទ័ពពិចារណា ចេះពិចារណាក្នុងយុទ្ធវិធីប្រយុទ្ធវាយកម្ទេចសត្រូវ។

[១០:៤១:៤៤]

សំណួររបស់ព្រះរាជអាជ្ញាគាត់សួរបន្ត៖ "ដូច្នេះមានន័យថា ប្រជាជនវៀតណាមទាំងអស់ហ្នឹងសុទ្ធតែជាទាហាន គឺថាដល់ទៅ៦០លាននាក់ គឺបានន័យថា អ៊ីចឹង តើនៅប្រទេសវៀតណាមហ្នឹងមានយោធាដល់ទៅ៦០លាននាក់ ឬក៏យ៉ាងម៉េច? ចម្លើយរបស់សាក្សីគាត់ឆ្លើយថា៖ មិនមានយោធា៦០លាននាក់ទេ ហើយនៅខ្មែរក៏មិនមានយោធា២លាននាក់ដែរ ក៏ប៉ុន្តែនេះគ្រាន់តែជាសុន្ទរកថា ដែលជំរុញឲ្យយោធាខ្មែរហ្នឹង ត្រៀមខ្សែប្រយុទ្ធតែប៉ុណ្ណោះទេ ដើម្បីឲ្យទទួលបានជ័យជម្នះ។"

អ៊ីចឹងខ្ញុំអានសម្រង់នេះឲ្យលោកស្តាប់នោះ លោកយល់ហើយពីបំណងរបស់ខ្ញុំ គឺថាលោកសាក្សីនោះគាត់បានស្តាប់អំពីសុន្ទរកថា នេះហើយគាត់បកស្រាយហើយ។ គាត់ថា វាមានកម្លាំងខុសគ្នារវាងយោធាទាំងពីរហ្នឹង គាត់មិនបាននិយាយពីប្រជាជនស៊ីវិលទេ។ អ៊ីចឹងសំណួររបស់ខ្ញុំចង់សួរដូចតទៅនេះជាសំណួរដែលអាចយកទៅអនុវត្តក្នុងវិស័យណាក៏បានដែរ នៅពេលយើងវិភាគអត្ថបទណាមួយ ទោះបីថាយើងជានរវិទ្យា ឬក៏អ្នកជំនាញខាងអំពើប្រល័យពូជសាសន៍ក៏ដោយ ថានៅពេលដែលយើងពិនិត្យឯកសារនេះជាបឋម នៅពេលដែលយើងមិនទាន់មានគោលជំហរណាមួយដែលមិនថា យ៉ាងណាកែប្រែឲ្យតែខាងបានអំពីការបកស្រាយនោះ អ៊ីចឹងយើងត្រូវតែយល់ពីបរិបទនៃការសរសេរអត្ថបទហ្នឹង ឬថ្លែងសុន្ទរកថាហ្នឹង។ ខ្ញុំសួរលោអ៊ីចឹង ថាតើនេះជា ការអនុវត្តសម្រាប់អ្នកជំនាញទាំងអស់ គឺថាត្រូវតែ

គិតពីបរិបទ ដោយមិនមានគំនិតណាមួយ គិតទៅតែផ្លូវម្ខាងរបស់ខ្លួនទេ តើអ៊ីចឹងមែនទេ?

[១០:៤៣:៥៧]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ! បាទហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំអរគុណដែលបានផ្ដល់មីក្រូឲ្យខ្ញុំមុន។ លោកស្រីមេធាវី អង់តា ហ្គីសសេ លោកអាចនិយាយបានដែរទេ ប៉ុល ពត ថ្លែងសុន្ទរកថាហ្នឹងទៅកាន់អ្នកណា ទៅកាន់តែយោធាទេ ឬក៏ចែក ពេលដែលគាត់ថ្លែងសុន្ទរកថាហ្នឹងក៏ថ្លែងទៅសម្រាប់មហាជនទូទៅទូលាយ?

**កញ្ញា អង់តា ហ្គីសសេ៖**

ដូចដែលខ្ញុំបានជម្រាបហើយ លោក ហ៊ីនតុន គាត់មានឯកសារហ្នឹងទាំងស្រុងតែម្ដងគឺជាឯកសារដែលគាត់ ជាសុន្ទរកថាដែលគាត់ថ្លែងទៅយោធា។ នៅទំព័រទី២ ជាភាសាបារាំង ខ្ញុំអត់មានលេខERNទេ គឺលេខាបក្សកុម្មុយនីស្តកម្ពុជាជាអ្នកថ្លែងនៅក្នុងឱកាសនៃការធ្វើបុណ្យខួបជ័យជម្នះ ១៧ មេសា កំណើតកម្ពុជាប្រជាធិបតេយ្យ ដ៏មហាអស្ចារ្យ និងរុងរឿង គឺថ្លែងទៅយោធា ហើយនិងវណ្ណៈពលករ កម្មករ។ អ៊ីចឹងគឺជាសុន្ទរកថាដែលថ្លែងជាទូទៅ មិនមានរឿងអីលាក់លៀមនោះទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** បើអ៊ីចឹងលោក ហ៊ីនតុន លោកចង់ឲ្យខ្ញុំចោទសំណួរនេះឡើងវិញម្ដងទៀត ឬក៏យ៉ាងម៉េច ឬក៏លោកចង់បញ្ចេញមតិឥឡូវតែម្ដង?

[១០:៤៥:៤៤]

**លោក អាឡិចសាន់ដឺ ហ៊ីនតុន៖**

**ឆ៖** សូមអរគុណលោកស្រី។ ខ្ញុំយល់ថា ខ្ញុំអាចឆ្លើយតបបានហើយ។ ហើយសូមអរគុណដែលរៀបចំ*ក្រណ្ឌ*ឯកសារផ្ដល់មកខ្ញុំ គឺថាវាមានជំនួយយ៉ាងសម្បើមដល់ខ្ញុំ។ ដូច្នេះទាក់ទងទៅចំណុចមួយរបស់លោកស្រី ដែលលើកឡើងអំពីចំណុចដ៏សំខាន់។ ខ្ញុំយល់ស្របថា ម្នាក់ៗដែលជាទស្សនវិទូគឺថា យើងបើកជំហាឲ្យមានការរិះគន់។ អ៊ីចឹងក្នុងនាមខ្ញុំជាទស្សនវិទូដែរនេះ គឺថាយើងបើកជំហាយ៉ាងដូច្នេះដែរ ដើម្បីឲ្យមានការរិះគន់ ការធ្វើសេចក្ដីវិនិច្ឆ័យ រិះគន់ណាមួយក៏វាឲ្យយើងរៀនសូត្រពីនេះដែរ។

ហើយយើងក៏ចង់បានថា តើតាមរយៈនេះ យើងនឹងទទួលបានព័ត៌មានអ្វីថ្មីៗថែមទៀត។ ទាក់ទងទៅនឹងឯកសារយោង ទៅលើបុគ្គលម្នាក់ មិនដឹងថាតើគាត់ឆ្លើយដោយប្រើពាក្យ “យួន” ឬក៏យ៉ាងណានោះទេ ឬក៏ប្រើពាក្យថា “ជនជាតិវៀតណាម” នោះទេ។ ដូចដែលខ្ញុំលើកឡើងពីខាងដើមអ៊ីចឹង ថាពាក្យនេះ “យួន” នេះអាចសំដៅទៅលើកងទ័ពវៀតណាម ក៏ដូចជាជនជាតិភាគតិចវៀតណាម។ ខ្ញុំអាចផ្តល់ការពន្យល់ពិភាក្សាឲ្យបានវែងឆ្ងាយ បើសិនជាអនុញ្ញាតឲ្យខ្ញុំពន្យល់វែងឆ្ងាយ ថាតើពេលនោះគេយល់ជាអវិជ្ជមានយ៉ាងដូចម្តេច។

អ៊ីចឹងខ្ញុំសូមរំឭកអំពីដែលខ្ញុំបានលើកឡើងពីខាងដើម។ ខ្ញុំសូមផ្តល់ឧទាហរណ៍នូវព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា នៅសហរដ្ឋអាមេរិក ពេលនោះគេមានប្រើពាក្យបែបញុះញង់អ៊ីចឹង គឺថាគ្រប់ទីកន្លែងដើម្បីឈានទៅដល់ការញុះញង់ទៅឲ្យមានការវាយប្រហារនេះ។ គេមានប្រើតាំងពីពាក្យថា “អាឆ្កែ” ឡើងទៅនោះ។ អ៊ីចឹងកាលណានិយាយសំដៅទៅលើជនជាតិវៀតណាម ឬក៏សំដៅទៅលើកងទ័ពវៀត-ណាម គឺអាស្រ័យទៅលើកិច្ចសម្ភាសន៍របស់បុគ្គលម្នាក់នេះ។ វាក៏សំដៅទៅលើជនជាតិវៀតណាមដែលរស់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។ ក្នុងសៀវភៅរបស់ខ្ញុំ ៗមានសរសេរវែង។ ហើយក្នុងចំណោមទស្សនវិទូ ក៏មានការចម្រូងចម្រាសគ្នា -- មិនមានការចម្រូងចម្រាសគ្នាចំពោះពាក្យនេះទេ ហើយក៏ដូចជានៅក្នុងមតិទូទៅរបស់ប្រជាជនកម្ពុជាផងដែរ។ ហើយចំពោះសំណើរបស់លោក នួន ជា ខ្ញុំរង់ចាំស្តាប់ប្រតិកម្មរបស់គាត់។ ដូច្នេះខ្ញុំគ្រាន់តែសុំបង្ហាញជំហររបស់ខ្ញុំឡើងវិញថា ឯកសារនេះ វាគឺថា គាំទ្រទៅដល់ទឡ្ហីករណ៍របស់ខ្ញុំហើយ។

[១០:៤៨:៥៨]

**សៈ** យើងដោយសារមានពេលវេលាតិច អ៊ីចឹងខ្ញុំត្រូវចូលទៅនិយាយអំពីប្រធានបទថ្មីមួយទៀត។ ឥឡូវខ្ញុំសូមចូលនិយាយអំពីចំណុចមួយដែលលោកបានឆ្លើយនៅទីនេះ ទាក់ទងទៅនឹងប្រជាជនថ្មី។ ខ្ញុំរង្វេងទំព័រ ដែលលោកបានលើកឡើងពីបញ្ហាប្រជាជនថ្មីនេះ នៅក្នុងសៀវភៅលោក។ លោកនិយាយថា នៅពេលខ្លះតាមបទពិសោធន៍របស់លោកនៅតំបន់៤១នោះ លោកបានឮមនុស្សម្នាក់ដែលលោកបានសម្ភាសថា ប្រជាជនថ្មី ពាក្យដែលគេប្រើអង្គាល់ណោះ គឺថាដូចជាឈ្លើយសឹក ឬក៏ទាសករ។ ខ្ញុំរកទំព័រនេះ ហើយឲ្យក្រុមការងារខ្ញុំជួយរកខ្ញុំ។ ខ្ញុំសូមនិយាយជាមួយលោកនូវអត្ថបទរបស់លោក ស្ទីវ ហេដឌ័រ គឺឯកសារ E3/3346។ សូមទោស ឥឡូវខ្ញុំរកឃើញហើយ រកឃើញកន្លែងសៀវភៅទំព័រនុ៎ងហើយ គឺទំព័រ៨៦ នៃសៀវភៅរបស់លោក ERN គឺឯកសារ E3/3346 ERN ជាភាសាអង់គ្លេសគឺ 00431528

។ លោកនិយាយជាភាសាអង់គ្លេសដូចតទៅនេះ៖ "ពេលខ្លះប្រជាជនថ្មី ក៏ត្រូវបាននិយាយយោងថាជាទាសករផងដែរ។ នៅពេលដែលគេសួរអ្នកណាម្នាក់ ថាតើអ្នកឯងស្ថិតក្នុងស្ថានភាពជាទាសករមែនទេ?" ខ្ញុំអានម្តងទៀត ព្រោះថាមានបញ្ហាបកប្រែជាភាសាបារាំង ដោយសារខ្ញុំនិយាយលឿនពេក ខ្ញុំបន្តលើកឡើងម្តងទៀត គឺទំព័រ៨៦ ឯកសារ E3/3346។ ខ្ញុំដកស្រង់៖ "ពេលខ្លះប្រជាជនថ្មីក៏ត្រូវបានគេនិយាយថា ជាទាសករផងដែរ។ តាមដែលយើងរក កំហឹង គឺថាយោងទៅតាមកំហឹងនោះ។ ហើយពាក់ព័ន្ធទៅនឹង ហាំង ង៉ោ គឺនៅពេលដែលគេសួរថា (តើធ្លាក់ក្នុងស្ថានភាពជាទាសករហើយឬនៅ?)។" បញ្ចប់ការដកស្រង់។

[១០:៥២:៣៣]

ខ្ញុំសូមប្រៀបធៀបសម្រង់នេះទៅនឹងសម្រង់នៃអត្ថបទរបស់លោក ហេដឌ័រ គឺឯកសារ E3/4527 ដែលលោកមាននៅសំណុំឯកសារនៅចំពោះមុខលោកនុំងហើយ។ ERN ជាភាសាអង់គ្លេស គឺធម្មតាមានក្រដាសពណ៌លឿងដែលខ្ញុំបិទចំណាំនៅនុំងហើយ ERN ជាភាសាអង់គ្លេសគឺ 00661462 ទៅដល់63, ERN ជាភាសាខ្មែរគឺ 00830768, ERN ជាភាសាបារាំងគឺ 00792921។ ខ្ញុំដឹងថា លោកបានអានឯកសារហ្នឹងហើយ ប៉ុន្តែឥឡូវនេះខ្ញុំដកស្រង់ផ្នែកនេះជាក់លាក់ ដោយសារផ្នែកនេះខ្ញុំចាប់អារម្មណ៍ ព្រោះ ស្ទីវ ហេដឌ័រ ហ្នឹងគាត់បានសរសេរប្រមូលផ្តុំឯកសារពីសម័យខ្មែរក្រហមច្រើន។ ហើយគាត់បានដកស្រង់អំពីអ្វីដែលគាត់រកប្រមូលបានហ្នឹង ជួនកាលជាកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ជាកាសែត ជាអីជាដើម ដែលនិយាយអំពីប្រជាជនថ្មី ហើយនិងបទបញ្ជាដែលបានចេញ ហើយដែលមានសរសេរនៅក្នុងឯកសារដែលគាត់រកឃើញទាំងអស់នោះទាក់ទងនឹងប្រជាជនថ្មី។ ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក។ ជាដំបូងទាក់ទងទៅនឹងសម្រង់របស់លោក ស្ទីវ ហេដឌ័រ ហ្នឹងដើម្បីធៀបជាមួយផ្នែកដែលខ្ញុំបានអានចេញពីសៀវភៅរបស់លោកអម្បាញ់មិញនេះ មុននឹងនិយាយអំពីប្រជាជនថ្មីខាងមុខទៀត។ ដើម្បីធ្វើឲ្យប្រជាជនថ្មីក្លាយជាផ្នែកបិតថេរមួយនៃប្លុកសាមគ្គី និងដ៏រឹងមាំមួយជាមួយរដ្ឋអំណាចបដិវត្តន៍ នោះកម្មាភិបាលមូលដ្ឋានត្រូវតែណែនាំឲ្យប្រកាន់យកតែទស្សនៈទូលំទូលាយជាមួយនឹងប្រជាជនដែលជម្លៀស ដោយមានលក្ខណៈបត់បែន ទន់ភ្លន់ និងមិនតឹងតែងជាមួយនឹងពួកគេ។ ជាពិសេស មិនត្រូវប្រព្រឹត្តលើពួកគេដូចជាឈ្លើយសឹកនោះឡើយ។ កម្មាភិបាលត្រូវតែទប់ស្កាត់ពីភាពមិនអត់ឱនរវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីដោយរៀបចំឲ្យពួកគេធ្វើការនៅជាមួយគ្នា "គឺក្នុងបរិយាកាសរីករាយ និងសាមគ្គីគ្នា"។ កម្មាភិបាលត្រូវដោះស្រាយជីវភាពរបស់ប្រជាជនថ្មីដើម្បីបង្ហាញ

ឲ្យគេឃើញថា របបនេះគឺជាកម្មសិទ្ធិរបស់ពួកគេ ហើយធានាថាប្រជាជនមូលដ្ឋានស្វាគមន៍ និងចែករំលែកដីធ្លី សត្វពាហនៈ និងចំណីអាហារជាមួយពួកគេ។ ប្រជាជនមូលដ្ឋានមិនត្រូវគេងប្រវ័ញ្ចកម្លាំងពលកម្មរបស់ប្រជាជនថ្មីឡើយ។ តែផ្ទុយទៅវិញ ត្រូវជួយដល់ប្រជាជនថ្មីដែលទើបតែមកកាន់ទីជនបទដែលមានតែដៃទទេ ដោយបង្ហាញឲ្យឃើញនូវកង្វះការយល់ដឹងទាំងស្រុងរបស់ពួកគេចំពោះអ្នកដែលទើបនឹងមកដល់ថ្មី។

[១០:៥៦:១០]

ដូច្នេះប្រជាជនថ្មី និងប្រជាជនមូលដ្ឋានត្រូវតែរស់នៅ រៀនសូត្រ និងមានពេលវេលាសប្បាយហើយនិងទទួលនូវការរីកចម្រើន ឬក៏ស៊ូទ្រាំនឹងភាពអត់ឃ្លាននៅក្នុងសហករណ៍ប្រមូលផ្ដុំជាមួយគ្នា។ កម្មាភិបាលត្រូវតែដាស់តឿន អប់រំកែប្រែប្រជាជនថ្មីឲ្យមានប្រសិទ្ធភាព។ បក្សត្រូវតែបង្ហាញឲ្យពួកគេឃើញថា បដិវត្តន៍គឺពិតជាកំពុងតែអនុវត្តសេដ្ឋកិច្ចស្មើភាពគ្នាដែលខ្លួនសម្រេចបាន។ គោលជំហរទាំងនយោបាយ ទាំងនេះត្រូវតែបញ្ចប់ទៅដល់រចនាសម្ព័ន្ធបក្សខាងក្រោម បញ្ជ្រាបទៅដល់រចនាសម្ព័ន្ធបក្សខាងក្រោម និងដែលណែនាំ ហើយត្រូវចាត់ទុកអ្នកជម្លៀសថ្មីទាំងនោះ ថាជាចំណែកមួយនៃប្រជាជនកម្ពុជា មិនមែនជាខ្មាំងទាំងអស់នោះទេ ហើយត្រូវរៀបចំចំណីអាហារទាំងអស់ ហើយរៀងកន្លែងស្នាក់នៅឲ្យគាត់បានស្មើគ្នាទាំងអស់។

ខ្ញុំមិនបានបង្ហាញអ្វីដែលសេរសេរនៅក្នុងអត្ថន្តរៈ ក៏ប៉ុន្តែនេះជាអ្វីដែលមានសរសេរ ហើយដកស្រង់ចេញពីឯកសារពីសម័យខ្មែរក្រហមតែម្ដង។ អ៊ីចឹងដោយជាក់ស្ដែងដែលយើងឃើញនឹងផ្នែកនេះ គឺថានៅក្នុងការងារស្រាវជ្រាវរបស់លោក ស្ទីវ ហេដឌ័រ នៅក្នុងបណ្ដុំឯកសារដែលគាត់បានពិគ្រោះ គឺថាមានឯកសារមួយចំនួនដែលបង្ហាញថាមានការណែនាំខុសពីអ្វីដែលត្រូវបានអនុវត្តនៅមូលដ្ឋាន។ អ៊ីចឹងសំណួររបស់ខ្ញុំ សំណួរទី១ របស់ខ្ញុំគឺថាទាក់ទងនឹងផ្នែកដែលខ្ញុំអាននេះ ហើយនិងកំណត់សម្គាល់ជើងទំព័រ ហើយដែលលោកដឹង បានពិគ្រោះឯកសារទាំងអស់ហ្នឹងហើយពី--។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថាអត្ថបទនេះ ដែលសរសេរដោយ ស្ទីវ ហេដឌ័រ មានចំណងជើងវែងណាស់ អត្ថបទគាត់ គឺថាការវាយតម្លៃឡើងវិញពីតួនាទីនៃអ្នកដឹកនាំជាន់ខ្ពស់ ហើយនិងមន្ត្រីមូលដ្ឋានចំពោះឧក្រិដ្ឋកម្មទាំងឡាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការទទួលខុសត្រូវរបស់កម្ពុជាក្នុងទស្សនវិស័យប្រៀបធៀប។ អត្ថបទនេះត្រូវបានបោះពុម្ពក្រោយពេលដែលលោកចេញសៀវភៅលោកហើយ។ តើ ខ្ញុំសួរលោកថាតើពេលក្រោយមកនោះលោកមានបានអានឯកសារហ្នឹងទេ? លោកមានធ្លាប់អានឯកសារហ្នឹងទេ? សំណួរទី១របស់ខ្ញុំ។

[១០:៥៨:៥៧]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាល់ទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់កាត់រំខានភ្លាមៗនោះទេ ក៏ប៉ុន្តែសំណួរដែលសួរមកកាន់លោកអ្នកជំនាញ គឺមិនសួរនៅក្នុងបរិបទចំកថាខណ្ឌដែលគាត់អាននោះទេ។ អ៊ីចឹងដើម្បីឲ្យគាត់យល់អំពីបរិបទរបស់អ្នកជំនាញ ស្មីរ ហេងឌ័រ ឲ្យបានពេញលេញ ដែលមេធាវីបានអានថា ទោះជាយ៉ាងណាក៏ដោយ ប្រជាជនថ្មីមិនត្រូវអនុញ្ញាតឲ្យមានសិទ្ធិនៅក្នុងជួរបក្សទេ រហូតទាល់តែមានស្មារតីប្រកាន់ជំហរបដិវត្តន៍ គឺពួកគេត្រូវតែស្ថិតនៅក្នុងសហករណ៍សិន។ ហេតុផលដែលខ្ញុំសួរបែបនេះ គឺសហព្រះរាជអាជ្ញាមិនមានឱកាសដើម្បីពិនិត្យមើលត្រង់កថាខណ្ឌនេះទេ។ ដូចមេធាវីការពារក្តីបានចោទសួរ ហើយមតិយោបល់ដែល ស្មីរ ហេងឌ័រ បានផ្តល់ឡើងនៅក្នុងកថាខណ្ឌដែលបានសួរហ្នឹង គឺក៏ជាចំណុចមួយដែលអ្នកជំនាញត្រូវគិតពិចារណាផងដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសហព្រះរាជអាជ្ញា គាត់ថា គាត់មិនចង់កាត់ផ្តាច់សម្តីខ្ញុំទេ ប៉ុន្តែគាត់បានធ្វើទៅហើយ។ ខ្ញុំចង់បញ្ជាក់ថា ខ្ញុំបានផ្តល់ឯកសារនេះទាំងស្រុងទៅគាត់ហើយ ទាំងមូលទៅគាត់ហើយ មិនមែនឲ្យតែសម្រង់នោះទេ។ អ៊ីចឹងគាត់យល់ពីបរិបទហើយ។ អ៊ីចឹងខ្ញុំគិតថា ព្រះរាជអាជ្ញាដូចមិនចាំបាច់ក្រោកឈរកាត់ផ្តាច់ខ្ញុំទេ។ ឯកសារហ្នឹង វានៅក្នុងបញ្ជីឯកសារពីដើមរបស់ខ្ញុំទៅហើយ។ អ៊ីចឹងបើសិនជាព្រះរាជអាជ្ញាចង់សួរគាត់ទាក់ទងនឹងអីទៀត គាត់អាចធ្វើបាន។ អ៊ីចឹងដើម្បីឲ្យច្បាស់ទាំងអស់គ្នា ខ្ញុំមិនបានដកស្រង់អត់ក្បាល អត់កន្ទុយទេ។ លោកអ្នកជំនាញនេះ គាត់បានឯកសារហ្នឹងទាំងមូលទៅហើយ ទាំងស្រុងទៅហើយ។ ហើយឯកសារនេះ មិនស្រួលគាត់ធ្លាប់អានពីមុនមកទៀតផង មុននឹងពេលដែលខ្ញុំដាក់ជូនដល់គាត់នោះ។

[១១:០១:៣១]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងសំណួរខ្ញុំសួរតែដដែលទេ គឺថា លោក ហ៊ីនតុន តើលោកបានពិគ្រោះឯកសារនេះ ពីមុនមកទេ? ហើយលោកមានបានឃើញពីសេចក្តីណែនាំ ឬក៏សេចក្តីបញ្ជាទាក់ទងទៅនឹងការអនុវត្ត

ចំពោះប្រជាជនថ្មីដែរឬទេ?

**លោក អាឡិចសាន់ឌឺ ហ៊ីនតុន៖**

**ឆ៖** សូមអរគុណលោកស្រី ហើយក៏អរគុណម្តងទៀតដែលបានឲ្យអត្ថបទមកខ្ញុំ ហើយដោយមានគូសពណ៌ចំណាំផង។ ខ្ញុំបានអានឯកសារជាច្រើន ពេលនេះហាក់បីដូចជាស្រពេចស្រពិលបន្តិចដោយសារមិនដឹងថា សំដៅទៅលើពេលវេលាមួយណា។ ដូចដែលខ្ញុំបានជម្រាបកាលម្សិលមិញ ខ្ញុំថាជឿជាក់ថា ថ្នាក់ដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា គឺថាគេមានគោលការណ៍របស់គេ ដើម្បីធ្វើម៉េចឲ្យសង្គមកម្ពុជាមានការជឿនលឿនទៅមុខ នៅក្នុងកម្រិតណាមួយ នៅក្នុងការសម្រួចសម្រាវសតិអារម្មណ៍បដិវត្ត។ ហើយក៏ជាការគួរឲ្យភ្ញាក់ផ្អើលផងដែរ ដែលក្នុងឆ្នាំ១៩៧៥នេះ ឯកសារបែបនេះ គឺខ្ញុំលើកឡើងពីម្សិលមិញហើយ។ ឯកសារបែបនេះក៏មាន ហើយមានរហូតមកដល់ឆ្នាំ៧៦, ៧៧ ដែលថាការបែងចែករចនាសម្ព័ន្ធដែលកើតចេញមកពីមនោគមន៍វិជ្ជាបក្សកុម្មុយនីស្តកម្ពុជាផង និងទៅតាមការរស់នៅជាក់ស្តែងនៅតាមមូលដ្ឋានផងដែរ។

[១១:០៣:១៧]

ខ្ញុំមិនចង់រៀបរាប់ច្រើនពេកទេ ក៏ប៉ុន្តែវាច្បាស់ណាស់ថា ប្រជាជននោះ គឺថាត្រូវតែប្រឹងប្រែងដើម្បីសម្រួចសម្រាវសតិអារម្មណ៍បដិវត្តរបស់ខ្លួន។ អ្នកខ្លះក៏គេយល់ឃើញថា មានការសម្រួចបានស្រួចស្រាល់ អ្នកខ្លះក៏មិនបាន។ ហើយកម្មាភិបាលដែលមានបុព្វសិទ្ធិ ដូចជានៅក្នុងសៀវភៅរបស់អៀង សារី ដែលខ្ញុំលើកឡើងជាភ័ស្តុតាងថា ម្នាក់ៗត្រូវតែធ្វើវិស្សុទ្ធកម្មខ្លួនឯង។ ត្រូវតែមាននិន្នាការនយោបាយ។ និន្នាការមួយផ្តោះទៅដល់ការសម្រួចនូវសតិអារម្មណ៍របស់ខ្លួន ដើម្បីធ្វើម៉េចឲ្យមានភាពបរិសុទ្ធ។ ក៏ប៉ុន្តែប្រជាជនថ្មី ខ្ញុំនេះ ខ្ញុំនិយាយអំពីភាពខុសគ្នា ដោយការកំណត់ទៅលើប្រជាជន។ ប្រជាជន គាត់យល់ហើយ ថាកន្លែងហ្នឹងគេកំពុងតែសម្រួចសម្រាវ ពង្រឹងឲ្យបានជាក់លាក់ នៅពេលផ្តោះទៅកាន់ដំណាក់កាលផ្សេងៗគ្នា។ ដូចខ្ញុំលើកឡើងថា នៅក្នុងឆ្នាំ៧៦ អ្នកដែលខ្ញុំរៀបរាប់នៅក្នុងឯកសារនេះ គឺគេអាចកែទម្រង់ខ្លួនឯង សម្រួចខ្លួនឯង។ ហើយនៅពេលដែលមានការសង្ស័យទៅដល់ការរដ្ឋប្រហារ វាកើតនាំឲ្យមានជំងឺត្រដេវរិច ហើយក៏ចាប់ផ្តើមធ្វើការបោសសម្អាតខ្មាំងផ្ទៃក្នុង។ ហើយក៏បានរកឃើញខ្មាំងផ្ទៃក្នុង ហើយក៏ត្រូវបានកម្ទេចសមាជិកតាំងពីលើទៅដល់ក្រោម ដូចជា ទិព នេះ គាត់បានធ្លាប់ចូលរួមប្រជុំនៅក្នុងតំបន់៤១ ជាមួយកម្មាភិបាលមួយចំនួន ដែលសហមេធាវីការពារក្តីក៏ជឿថាឈ្មោះ ទិព នេះក៏បានចូលរួមប្រជុំមែននៅក្នុងដំណើរការមួយ ដែលគេត្រូវបានកំណត់ប្រជាជន ថាអ្នក

នេះមានភាពពីអ្នកនោះ។ ជាពិសេសអ្នកដែលមិនងាយនឹងសម្រួចសម្រាវសតិអារម្មណ៍របស់ខ្លួនផងដែរ ដែលនាំឲ្យគេហៅថាមានភាពកកក់ល្អនៅក្នុងជួរបដិវត្តន៍ នៅពេលនោះក៏ចាប់ផ្ដើមមានការបោសសម្អាត។

[១១:០៥:៣០]

ក៏ប៉ុន្តែអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ អ្នកនិស្សិតបញ្ញវន្ត អ្នកដែលមានវណ្ណៈគ្រួសារខ្ពស់ខ្ពស់ ខ្ញុំបានលើកឡើងនៅក្នុងសៀវភៅរបស់ខ្ញុំ គឺហើយក៏គេមានស្រង់ប្រវត្តិរូបមនុស្ស ក្នុងនោះមានប្រជាជនថ្មីហ្នឹង និងប្រជាជនចាស់។ អ្នកថ្មីហ្នឹង គឺថាសង្ស័យថាជាប់ពាក់ព័ន្ធជាមួយចក្រពត្តិនិយម មូលធននិយម ហើយក៏គេយោងថាប្រជាជនថ្មីនេះ គឺជាពួកបញ្ញើក្អែក។ អ៊ីចឹងក្នុងស្មារតីដែលត្រូវពិនិត្យមើលទៅលើឯកសារនេះទាំងស្រុង គឺរបស់ ស្ទីវ ហេដឌ័រ នេះ គាត់ក៏និយាយថា ជនជាតិចិននៅពេលនោះ ក៏ក្លាយទៅជាការកំណត់គោលដៅដែរ។ ហើយ ប៉ែន ឃៀរនិន គាត់ថា នេះក៏ជាចំណុចមួយដែលនាំបង្កើតឲ្យមានអំពើប្រល័យពូជសាសន៍ផងដែរ។ អ៊ីចឹងអត្ថបទរបស់ ស្ទីវ ហេដឌ័រ គឺយើងយកមកពិភាក្សាគ្នាពីមុននេះ ទើបយកពិភាក្សាមុននេះ បន្តិចនេះឯង។

**ស៖** សូមអរគុណដែលបានធ្វើអត្ថាធិប្បាយដ៏វែងអន្លាយ។ អ្វីដែលខ្ញុំចង់បាននោះ គ្រាន់តែចង់បានមតិរបស់លោកទាក់ទងនឹងពាក្យដែលប្រើតំបន់៤១ ដែលវាខុសពីសេចក្ដីណែនាំដែលបានផ្ដល់នៅក្នុងឯកសារមួយចំនួន។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ថា ស្ទីវ ហេដឌ័រ បានផ្ដល់សក្ខីកម្មនៅទីនេះ នៅក្នុងសំណុំរឿង០២/១។ អ៊ីចឹងខ្ញុំសូមផ្ដោតមកនិយាយតែជាមួយលោកពីការងារលោក ការងារស្រាវជ្រាវរបស់លោកវិញ ហើយនិងមតិយោបល់លោកវិញ ជាជាងការធ្វើការអត្ថាធិប្បាយទៅលើអ្នកនិពន្ធ អ្នកស្រាវជ្រាវផ្សេងទៀត។ មានចំណុចមួយទៀត ជាមួយនឹងទង់បដិវត្តដែរ ហើយនិងទង់យុវជនបដិវត្តកម្ពុជាដែរ។ លោកបានប្រើពាក្យ ប្រើទង់បដិវត្តហ្នឹងមួយចំនួនដែរ មិនច្រើននោះទេ។ ដោយសារអង្គាល់នោះ គឺថាពេលដែលលោកស្រាវជ្រាវនោះ វាមានការលំបាកក្នុងរកឯកសារ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់សួរលោកនោះគឺ ទង់យុវជនយុវនារីឆ្នាំ១៩៧៧ ដែលលោកបានប្រើ។

[១១:០៧:៥៩]

អ៊ីចឹងខ្ញុំសួរថា ទាក់ទងទៅនឹងទស្សនាវដ្ដីទង់បដិវត្ត ហើយនិងយុវជនយុវនារីបដិវត្តនេះ ជាប្រធានបទដែលលោកបានប្រើសិក្សាក្នុងពេលដែលលោកទៅសម្ភាសប្រជាជននៅតំបន់៤១ ដែរឬទេ? អ៊ីចឹងពេលដែលលោកចោទសំណួរទៅប្រជាជនទាំងអស់ហ្នឹង តើលោកមានបានបង្ហាញទស្សនាវដ្ដីទាំង

អស់ហ្នឹងទេ? លោកមានបានពិគ្រោះទស្សនាវដ្តីហ្នឹងជាមុនទេ? ហើយបើមិនអ៊ីចឹងទេ អ្នកណាអ្នកបានពិគ្រោះទស្សនាវដ្តីហ្នឹងជាដើម ពេលដែលលោកធ្វើការសម្ភាស?

**ឆ៖** សូមអរគុណលោកស្រីមេធាវី។ ខ្ញុំសូមបញ្ជាក់ចំណុចមួយគឺ ហាំង ង៉ោ ខ្ញុំជឿជាក់ថានៅបាត់ដំបង គាត់បានសរសេរអនុស្សរណៈមួយ ខ្ញុំបានស្រង់សាររបស់គាត់។ ចម្លើយលឿន គឺថាខ្ញុំមិនបានទទួលឯកសាររបស់គាត់នេះទេ។ ដូច្នេះគោលបំណងរបស់ខ្ញុំ គឺព្យាយាមស្វែងយល់អំពីបទពិសោធន៍ក្នុងការរស់នៅប្រជាជននៅក្នុងភូមិទាំងនេះ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ក្រៅពីបទពិសោធន៍នេះក៏មានក្របខ័ណ្ឌមួយដែលធ្វើឲ្យខ្ញុំយល់អំពីព្រឹត្តិការណ៍ទាំងឡាយដែលបានកើតមានឡើង។ ពាក្យពេចន៍ដែលបានប្រើប្រាស់បញ្ជាក់បទពិសោធន៍របស់គាត់ គឺតែងតែប្រើប្រាស់ថាមានប្រើពាក្យថា "ប្រជាជនមូលដ្ឋាន ប្រជាជនចាស់ ប្រជាជនថ្មី ប្រជាជន១៧មេសា"។ ពាក្យទាំងអស់នេះត្រូវបានគេកំណត់យកមកប្រើប្រាស់ ហើយគេបទពិសោធន៍របស់គាត់ គឺថាគាត់តែងតែលើកឡើងនិយាយពាក្យពេចន៍ទាំងអស់នេះ។ ហើយគាត់បញ្ជាក់ថា មានការញែកដាច់ពីគ្នាមែនរវាងប្រជាជនថ្មី និងប្រជាជនចាស់ ហើយក៏មានការបោសសម្អាត ជួនកាលប្រជាជនថ្មីនេះ គឺថាយកទៅទាំងគ្រួសារ ទាំងគ្រួសារតែម្តង។

[១១:១០:០០]

**ស៖** ខ្ញុំសូមអភ័យទោស លោក ហ៊ីនតុន ពីព្រោះថាពេលវេលាកាន់តែទៅមុខ អ៊ីចឹងខ្ញុំសូមផ្តោតទៅលើតែបញ្ហាសំខាន់ៗ។ លោកបានឆ្លើយកាលពីមុនហើយ លោកបានសួរ ខ្ញុំសួរថា លោកបានចោទសំណួរសួរទៅនឹងការពិគ្រោះឯកសារទស្សនាវដ្តីអីនេះជាដើមទេ។ ហើយនៅពេលដែលលោកឆ្លើយហើយហ្នឹង ខ្ញុំសូមផ្តាច់លោក ព្រោះថាពេលវេលាខ្ញុំហ្នឹងខ្លីណាស់លោក។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយនៅទំព័រ២៦៥ នៃសៀវភៅរបស់លោក ដែលត្រូវបានបង្ហាញដោយមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងផ្នែកហ្នឹងគឺថា បាននិយាយអំពីការដោះដូរកម្មសិទ្ធិ។ ឥឡូវខ្ញុំដកស្រង់តែម្តង ហើយចាំឲ្យលោកធ្វើការអត្ថាធិប្បាយ លោកបាននិយាយអំពីអំណាចផ្តាច់ការ ពីការរបបគោរពម្ចាស់ទឹក ម្ចាស់ដីអីជាដើម។ នៅពេលដែលលោកនិយាយពីតំបន់៤១នោះ លោកនិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសនៅចុងទំព័រ លោក៖ "ខ្មែរក្រហមហាក់បីដូចទទួលស្គាល់ថា បែបបទនេះ ហើយដើម្បីការពារកុំឲ្យខ្លាំងរត់រួចបាន ជាពិសេស ជាទូទៅទាហានគឺថាត្រូវតែប្រគល់សិទ្ធិអំណាចឲ្យពួកគាត់។" បញ្ចប់ការដកស្រង់។ អ៊ីចឹងក្រៅពីតំបន់៤១នោះ តើលោកមានយោងទៅអ្វីខ្លះ ដើម្បីសរសេរផ្នែកហ្នឹងនៃសៀវភៅលោកនោះ?

[១១:១២:០៥]

**ឆ៖** សូមអរគុណលោកស្រីមេធាវី។ ជាថ្មីម្តងទៀត គោលបំណងរបស់ខ្ញុំ គឺស្វែងយល់អំពីបទពិសោធន៍ប្រជាជនរស់នៅក្នុងតំបន់នេះ ដើម្បីបង្ហាញអំពីបញ្ហាប្រវត្តិសាស្ត្រដែលបានកើតមានឡើងក្នុងលក្ខណៈទ្រង់ទ្រាយធំដែរនេះ គឺថាខ្ញុំនិយាយនេះ សំដៅទៅលើកិច្ចសម្ភាសន៍របស់ខ្ញុំដែលខ្ញុំបានសម្ភាសជាមួយបុគ្គលទាំងអស់នេះ ហើយដូចខ្ញុំបានឆ្លើយពីខាងដើម គឺថាពិបាកក្នុងការសម្ភាសជាមួយនឹងអតីតកម្មាភិបាលខ្មែរក្រហមណាស់ បើទោះណាខ្ញុំបានសម្ភាសខ្លះក៏ដោយ។ ដូច្នេះសូមកំណត់បញ្ជាក់ឯកសារមានឯកសារជាច្រើនខ្ញុំបង្ហាញទៅដល់សេចក្តីសន្និដ្ឋានរបស់ខ្ញុំ រួមមានការបោសសម្អាតនៅតំបន់៤១ ហើយនិងការសម្លាប់ជនជាតិចាម។ ដូច្នេះ ខ្ញុំតែងតែបង្ហាញក្នុងរបៀបនេះឯង ដើម្បីជាព័ត៌មានមួយ ហើយក៏ជាភ័ស្តុតាងមួយសម្រាប់ការពិចារណារបស់អង្គជំនុំជម្រះផងដែរ។

**ស៖** សំណួរខ្ញុំច្បាស់ជាងនេះលោកអំមិញហ្នឹង ខ្ញុំសួរថា ក្រៅពីតំបន់៤១នេះ តើលោកមាននិយាយពីកន្លែងផ្សេងទៀតទេ ឬក៏ការសន្និដ្ឋានរបស់លោកហ្នឹងយោងតែទៅលើការស្រាវជ្រាវរបស់លោក នៅតំបន់៤១ នេះទេ?

[១១:១៣:៤៦]

**ឆ៖** សូមអរគុណលោកស្រី។ ខ្ញុំមិនអាចពិនិត្យមើលទំព័រណាមួយ ឲ្យបានច្បាស់លាស់នោះទេ ក៏ប៉ុន្តែមិនអីទេ ខ្ញុំមិនបានសម្ភាសតែប្រជាជននៅក្នុងស្រុកកំពង់សៀមតំបន់៤១ តែប៉ុណ្ណោះ។

**ស៖** អរគុណដែលបានឆ្លើយបញ្ជាក់ដូចនេះ។ ខ្ញុំចេះតែផ្តោតទៅលើចំណុចជាក់លាក់ហ្នឹង ដោយសារយើងមានជាក់លាក់ លោកសហភាតារបស់ខ្ញុំក៏អ៊ីចឹងដែរ។ ឥឡូវមានសំណួរទូលាយទាក់ទងនឹងនរវិទ្យាបន្តិចដែរ។ លោកបាននិយាយជាមួយសហព្រះរាជអាជ្ញា ពីអំពីបញ្ហាពីចម្រៀងជាតិជាដើម នៅទំព័រ២៦៧ នៃសៀវភៅរបស់លោកគឺ ERN ជាភាសាអង់គ្លេសគឺ 00431709។ លោកអត់មានសៀវភៅនៅនឹងដៃលោកទេឬ?

ខ្ញុំស្មានតែលោកមានសៀវភៅនៅក្នុងដៃ។ បើអ៊ីចឹង -- អ៎! ខាងព្រះរាជអាជ្ញាមានសៀវភៅ។ ខ្ញុំឃើញថាព្រះរាជអាជ្ញា អ៊ីចឹងគឺទំព័រ២៦៧ នៅសៀវភៅរបស់លោកនេះ ដែលក្នុងទំព័រហ្នឹង លោកនិយាយអំពីការបរិច្ចាគឈាម បង្ហូរឈាម ពលី។ នៅក្នុងចម្រៀងជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ លោកបានធ្វើការអធិប្បាយជាច្រើនដង ដែលនិយាយអំពី លើកឧទាហរណ៍នៅ ដាំ ផេង គឺការធ្វើជំរុញមនុស្សមានវីរភាពស្មោះស្ម័គ្រនឹងជាតិ។ អ៊ីចឹងខ្ញុំសួរលោកថា តើនៅខ្លឹមសារបែបនេះហ្នឹង វាមានចំពោះ

កម្ពុជាប្រជាធិបតេយ្យទេ ឬក៏គ្រប់រដ្ឋទាំងអស់ ឬក៏សង្គមទាំងអស់លើលោកដែលធ្វើបដិវត្តន៍ ហើយប្រឆាំងនឹងអាណានិគមនិយម ឬក៏ប្រទេសដែលមានធ្វើសង្គ្រាមដើម្បីរំដោះប្រទេសរបស់ខ្លួនចេញពីរបបអាណានិគមអីជាដើមនេះ? អ៊ីចឹងខ្ញុំចង់សួរលោកថា តើវាមិនរឿង ជារឿងធម្មតា ឬក៏យ៉ាងម៉េចពីព្រោះថាត្រូវនិយាយអំពីការពលីអីជាដើមនេះ? ឧទាហរណ៍ដូចនៅប្រទេសបារាំង ចម្រៀងជាតិនោះចំណងជើង *"ម៉ាកសីយេស"* អីហ្នឹង គឺក៏ជំរុញឲ្យប្រជាជនកាន់អាវុធអីជាដើមដែរ ហើយដើម្បីបំបាត់ឈាមអាក្រក់ពួកសត្រូវអីជាដើម។ ហើយចម្រៀងជាតិអាមេរិកាំងក៏ដូចគ្នាដែរ និយាយពីឈាមវីរជនឈាមអាក្រក់របស់ខ្មាំងអីជាដើមដែរ។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើវាមិនមែនជារឿងធម្មតាទេឬ ដែលនៅក្នុងចម្រៀងជាតិហ្នឹងវាតែងតែមានខ្លឹមសារបែបនេះហើយ ការជំរុញឲ្យមនុស្សពលីអីជាដើមនេះមិនអ៊ីចឹងទេឬ?

[១១:១៧:១៧]

**ឆ៖** សូមអរគុណលោកស្រី។ ហើយសូមអរគុណចំពោះការលើកឡើងនូវបញ្ហាដ៏សំខាន់។ នៅពេលដែលយើងពិនិត្យមើលអំពើប្រល័យពូជសាសន៍ឲ្យបានវែងឆ្ងាយ យើងពិនិត្យមើលលទ្ធិវែងឆ្ងាយមួយ ដោយមិនមើលទៅលើបរិបទនេះ យើងជឿជាក់ថា យើងយល់អំពីបរិបទនេះ។ ដើម្បីឲ្យយល់ថាតើអត្ថន័យនៃចម្រៀង អត្ថន័យនៃអព្ភូតហេតុផ្សេងៗ ព្រឹត្តិការណ៍ផ្សេងៗនៃការបែងចែកវណ្ណៈ យើងត្រូវតែមើលបរិបទនៅមូលដ្ឋានតែម្តង។ វាងាយស្រួលទេ ក្នុងការស្វែងរកប្រភពប្រហាក់ប្រហែលគ្នា ក៏ប៉ុន្តែយើងត្រូវតែវែកញែកឲ្យបានច្បាស់លាក់ មនោគមន៍វិជ្ជា ចេញពីចម្រៀង របាំ ហើយនិងការរស់នៅក្នុងកម្រិតមួយឲ្យបានទូលំទូលាយ គឺក្នុងកម្រិតមួយដែលវាភ្ជាប់ទៅនឹងការញុះញង់ឲ្យមានកំហឹង ដូចជាគេនិយាយអំពីសញ្ញាណនៃការបង្ហូរឈាម។ ខ្ញុំបានលើកឡើងនិយាយមកហើយ គឺនិយាយអំពីបែងចែកវណ្ណៈ។ នេះគឺខ្ញុំនិយាយអំពី នៅកន្លែងមួយគឺភូមិដាំផេងនេះ។ កម្មាភិបាលខ្មែរក្រហមក៏បានលើកឡើងអំពីចំណុចទាំងនេះ គឺគេនិយាយគ្នាអំពីការបែងចែកវណ្ណៈនេះឯង។ ហើយបើនិយាយអំពីឈាមក្រហមឆ្អៅ ឈាមក្រហមឆ្អៅបានក្លាយទៅជាកំហឹងតស៊ូឥតស្រាកស្រាន្ត។ អ៊ីចឹងយើងពិនិត្យមើលទៅលើឯកសារនេះឲ្យបានច្បាស់លាស់ ដោយពាក់ព័ន្ធទៅនឹងកត្តាវប្បធម៌ និងកត្តាប្រវត្តិសាស្ត្រ។ យើងមិនមែនគ្រាន់តែធ្វើការសន្និដ្ឋាន ហើយធ្វើការនិយាយបូកសរុបជារួមបាននោះទេ។ ដូច្នេះស្រួលណាស់ ក្នុងការស្វែងយល់អំពីចំណុចនេះ ក៏ប៉ុន្តែវាពិបាកពាក់ព័ន្ធទៅនឹងគោលបំណង ទាក់ទងទៅនឹងមនោគមន៍វិជ្ជាណាមួយនោះ។

[១១:១៩:៤៧]

**ស៖** ខ្ញុំត្រូវតែធ្វើយ៉ាងម៉េចឲ្យខ្លីបន្តិច។ ចម្លើយលោកនោះគឺថាយើងមិនអាចប្រៀបធៀបបរិបទបដិវត្តន៍ គឺពេល ឧទាហរណ៍ដូចជាការគេធ្វើចម្រៀងជាតិបារាំងជាដើម ហើយនិងចម្រៀងជាតិនៅអាមេរិកអីជាដើមនោះ លោកនិយាយថាមិនអាចប្រៀបធៀបគ្នាបានទេ ដោយសារបរិបទខុសគ្នា។ ខ្ញុំសូមទោស ខ្ញុំសួរសំណួរអ៊ីចឹង លក្ខណៈបិទហ្នឹង ពីព្រោះថាសហភាតាខ្ញុំគាត់មានសំណួរចង់សួរដែរលោក។

**ឆ៖** ខ្ញុំសូមឆ្លើយតប ដូចជាខ្ញុំលើកឡើងពីមុនហើយ ពាក់ព័ន្ធទៅនឹងបញ្ហានរវិទ្យា គឺយើងស្វែងយល់មុននឹងធ្វើការវិនិច្ឆ័យ គឺថាតើអ្នកមូលដ្ឋានគាត់យល់យ៉ាងដូចម្ដេច ដើម្បីយកបញ្ហាទាំងអស់នេះមកប្រៀបធៀប។ ហើយក្រោយពីការព្យាយាមយល់អំពីបទពិសោធន៍របស់អ្នកស្រុក អ្នកភូមិ ហើយទើបយើងធ្វើការវិនិច្ឆ័យ ដូចជាការប្រើ -- និយាយអំពីជំងឺបាក់ស្បាតដែលគាត់ទទួលបានជាដើម ។ល។ បើមិនយល់អំពីជីវភាពរស់នៅ ដូចជាការកើតមាននូវជំងឺបាក់ស្បាតនេះជាដើម ។ល។ នោះគឺមិនអាចធ្វើទៅបានទេ។ សៀវភៅរបស់ខ្ញុំបង្ហាញច្បាស់ហើយថា តើយើងយកបទពិសោធន៍នៅតាមមូលដ្ឋាននេះ ហើយដើម្បីយកវាមកប្រៀបធៀបនូវលក្ខណៈជាទូទៅបានដោយរបៀបណា? ខ្ញុំយល់ឃើញថាសៀវភៅរបស់ខ្ញុំសរសេរបានច្បាស់លាស់ហើយ ពាក់ព័ន្ធទៅនឹងចេតនាក្នុងការផ្ដោតទៅលើរបៀបរបបគំរូរស់នៅពាក់ព័ន្ធទៅនឹងកត្តាភូមិសាស្ត្រ កត្តាប្រជាសាស្ត្រនៅតំបន់នោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមានសំណួរច្រើនទៀតដែលត្រូវសួរទៅលោក ក៏ប៉ុន្តែឥឡូវនេះខ្ញុំសូមផ្ដល់វេទិកាទៅសហភាតារបស់ខ្ញុំសិន។

[១១:២២:០០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាត។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំ គង់ សំអុន ជាសហមេធាវីការពារក្ដីរបស់លោក ខៀវ សំផន។ សូមជម្រាបសួរលោកអ្នកជំនាញលោក ហ៊ីនតុន។ ខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងការពិភាក្សាគ្នាក្នុងរយៈពេលបីថ្ងៃកន្លងមកនេះ។ ជាដំបូងខ្ញុំចង់សួរបញ្ជាក់ទៅលើពាក្យដែលលោកបានអះអាងថា ពាក្យប្រើប្រាស់ថា

"យួន" គឺជាការប្រកាន់ពូជសាសន៍ ហើយក៏ជាការញុះញង់។ អ៊ីចឹងខ្ញុំចង់សួរលោកជាលក្ខណ:ទូទៅសិនថា តើពាក្យ "យួន" នេះ ខ្មែរចាប់ប្រើពីពេលណា? លោកដឹងទេ?

**លោក អាឡិចសាន់ឌឺ ហ៊ីនតុន៖**

**ឆ៖** សូមអរគុណលោកមេធាវី។ ខ្ញុំមិនអាចប្រាប់ពេលវេលាចាប់ពីពេលណាឲ្យច្បាស់លាស់នោះទេ ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងភាពជាក់លាក់ក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ និងឆ្នាំមុនៗ និងឆ្នាំក្រោយៗមកទៀត គឺគេមានពាក្យនិយាយលម្អិតអំពីពាក្យនេះហើយ។

**ស៖** លោកអាចបញ្ជាក់ពីរយៈពេលទាក់ទងទៅនឹងអំឡុងពេលថា វាវែងប៉ុនណា រាប់រយឆ្នាំ រាប់ពាន់ឆ្នាំ ឬមួយក៏ទើបតែថ្មីៗនេះបានទេ?

[១១:២៣:៥៣]

**ឆ៖** សូមអរគុណលោកមេធាវី។ ជាថ្មីម្តងទៀតក្នុងឋានៈជាទស្សនវិទូ ខ្ញុំតែងតែពិនិត្យពិច័យល្អិតល្អន់មុននឹងខ្ញុំផ្តល់យោបល់ទៅលើចំណុចនេះ។ តាមការសិក្សារបស់ខ្ញុំ ការប្រើពាក្យ "យួន" គឺនៅបណ្តាឆ្នាំ តាំងពីបណ្តាឆ្នាំមុនៗមកម្ល៉េះ គឺជាពិសេសនៅក្នុងរបបសាធារណរដ្ឋខ្មែរ និងចូលមកដល់របបកម្ពុជាប្រជាធិបតេយ្យ។ វាជាសំណួរមួយល្អ ដូចដែលខ្ញុំបានលើកឡើង គឺថាវាអាស្រ័យទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ បរិបទ ពេលវេលា ដែលគេត្រូវបានប្រើនៅក្នុងចរិតលក្ខណៈមួយខុសៗគ្នា ក៏ប៉ុន្តែក្នុងប្រវត្តិសាស្ត្រកម្ពុជា ពាក្យ "យួន" នេះត្រូវបានគេយកមកប្រើប្រាស់ គឺថាសំដៅនាំទៅឲ្យមានការរើសអើង សំដៅទៅលើជនជាតិភាគតិចវៀតណាម។

**ស៖** បាទសូមអរគុណ។ នៅពេលដែលលោកធ្វើការសន្និដ្ឋានទៅលើការប្រើប្រាស់ពាក្យ "យួន" ជាភាសាខ្មែរនេះ តើលោកបានពិនិត្យទៅលើវចនានុក្រមខ្មែរ ជាពិសេសគឺវចនានុក្រមរបស់សម្តេច ជួន ណាត ដែលបោះពុម្ពតាំងពីឆ្នាំ៦២ មកកន្លងមក បោះពុម្ពហូរហែមកដោយពុទ្ធសាសនបណ្ឌិត្យ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យរបស់កម្ពុជាដែរទេ ក្នុងការដែលលោកពិនិត្យទៅលើការប្រើប្រាស់ពាក្យ ឬក៏ភាសាខ្មែរដែលហៅថា "យួន" នេះ?

**ឆ៖** សូមអរគុណលោកមេធាវីការពារ។ ពិតណាស់ គឺការពិនិត្យមើលទៅលើវចនានុក្រម គឺជារឿងមួយសំខាន់ណាស់។ ខ្ញុំបានពិនិត្យទៅលើវចនានុក្រម សូមទោសគឺថាខ្ញុំមិនបានពិនិត្យមើលវចនានុក្រមដែលលោកបានលើកឡើងនោះទេ។ មូលដ្ឋានរបស់ខ្ញុំនោះ គឺការសន្ទនា និងកិច្ចសម្ភាសន៍របស់ខ្ញុំជាមួយប្រជាជនកម្ពុជា រួមមានប្រជាជននៅតំបន់៤១ ក៏ដូចជាប្រភពឯកសារបន្ទាប់បន្សំដ៏ច្រើន

ទៀតក្នុងការប្រើប្រាស់ពាក្យពេចន៍នេះ។ ពាក្យនេះគឺថាត្រូវបានគេប្រើប្រាស់ឡើងក្នុងរូបភាពជាការញុះញង់ក្នុងពេលដែលខ្ញុំធ្វើការសិក្សាស្រាវជ្រាវ។

**ស៖** បាទ សូមអរគុណ។ លោកមានធ្លាប់ឮពាក្យខ្មែរដែលប្រើពាក្យយួននេះ ភ្ជាប់ជាមួយនឹងពាក្យដទៃទៀត ឧទាហរណ៍ដូចជាយួនអណ្ណាម យួនតុងកឹង ឬក៏យួនព្រៃនគរអីជាដើមទេ លោកធ្លាប់ដែលឮការប្រើប្រាស់ពាក្យជាភាសាខ្មែរហ្នឹងទេ?

[១១:២៧:០១]

**ឆ៖** សូមអរគុណលោកមេធាវីការពារក្ដី។ ការប្រើប្រាស់ដទៃៗទៀត គឺថាមានប្រើមែន ប៉ុន្តែជាញឹកញាប់ បញ្ហាដែលខ្ញុំជួបប្រទះក្នុងពេលខ្ញុំស្រាវជ្រាវឆ្នាំ៩៤-៩៥ គឺការប្រើប្រាស់ពាក្យ "យួន" នេះសំដៅទៅលើជនជាតិភាគតិចវៀតណាម។ កាលណា ខ្ញុំនិយាយតែការវិភាគរបស់ខ្ញុំក្នុងពេលនោះទេ។ ខ្ញុំសំដៅទៅលើអំឡុងពេលខ្ញុំសិក្សាស្រាវជ្រាវ មានទស្សនវិទូមួយចំនួន ដែលខ្ញុំបានលើកយោងនៅក្នុងការសិក្សារបស់ខ្ញុំ គឺសំដៅទៅលើ គេហៅថាការញុះញង់ឲ្យមានការស្អប់ខ្ពើមរើសអើងពូជសាសន៍ភ្ជាប់ទៅនឹងពាក្យនេះ។ ដូចខ្ញុំជម្រាបជូនខាងដើម ពាក្យ "យួន" នេះ នៅពេលនោះអាចប្រើប្រាស់ដែលពេលនោះគឺថាមិនមានការរើសអើងដល់ថ្នាក់របៀបនេះនោះទេ។ ខ្ញុំបង្ហាញច្បាស់ហើយតាំងពីដើមទីមក ថាដើម្បីឲ្យយល់អំពីការប្រើប្រាស់ពាក្យ "យួន" នៅក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលពាក្យហ្នឹង គេប្រើមកនៅក្នុងលក្ខណៈជាមនោគមន៍វិជ្ជាដើម្បីញុះញង់ឲ្យមានការស្អប់ គឺគេប្រើប្រាស់ក្នុងសម័យសាធារណរដ្ឋ ហើយនៅក្នុងបរិបទនយោបាយ គឺសំដៅទៅលើជនជាតិវៀតណាមក្នុងលក្ខណៈទ្រង់ទ្រាយធំ ដើម្បីឲ្យស្អប់ និងដើម្បីញុះញង់ឲ្យមានការស្អប់តាមរយៈការផ្សព្វផ្សាយជាសារនយោបាយ និងជាការឃោសនា។ ហើយពាក់ព័ន្ធទៅនឹងការបោសសម្អាត ដឹកឫសខ្មាំង គឺវាមានការប្រើប្រាស់ពាក្យនេះដើម្បីដុតកំហឹងទៅលើជនជាតិវៀតណាម។ ខ្ញុំបាននិយាយហើយ ពាក្យប្រើប្រាស់យួននេះ គឺសំដៅទៅលើជាតិសាសន៍ ភាសា ហើយនិងការ គេហៅថាការស្អប់ខ្ពើមចំពោះជនជាតិវៀតណាម។ ដូចខ្ញុំបានលើកឡើងពីខាងដើម វាអាចមានការប្រើប្រាស់ពាក្យ "យួន" ដោយថាមិនបានគិតថាវាជាយ៉ាងណាយ៉ាងណពីនោះទេ វាអាច។ ក៏ប៉ុន្តែក្នុងបរិបទធំនោះ ទូលំទូលាយនោះ គឺៗជាការរើសអើងហើយ ក៏ប៉ុន្តែពាក្យនេះក៏វាអាចប្រើប្រាស់ខុសគ្នាដែរ។

**ស៖** បាទ ភ្ជាប់នឹងចំណុចនេះ ខ្ញុំសួរសំណួរតូចមួយគឺទាក់ទងទៅនឹងមុខម្ហូបខ្មែរ លោកដែលធ្លាប់សាកសម្ដម្ហូរយួនដែរទេ?

[១១:២៩:៥១]

**ឆ៖** សូមអរគុណលោកមេធាវីការពារក្ដី។ ខ្ញុំដឹងពាក្យនេះ ក្នុងនាមជានរវិទូ ខ្ញុំគិតវាទៅតាមរូបភាពផ្សេងៗ។ ខ្ញុំមិនចង់ធ្វើការវិភាគវែងឆ្ងាយ ដោយពាក់ព័ន្ធទៅនឹងថាតើខ្ញុំធ្លាប់សាកហួបសម្ភាសយួនដែរ ឬក៏អត់នោះទេ។ ខ្ញុំយល់ពាក្យនេះ ខ្ញុំយល់ ធ្លាប់ឮ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ចំពោះពាក្យដែលខ្មែរហៅយួន ដែលមានលក្ខណៈជាការរើសអើង ជាការប្រមាថ លោកអាចបញ្ជាក់បានទេ មានពាក្យអ្វីដែលខ្មែរប្រើ ហើយដែលយើងមើលទៅអាចយល់ថា ជាពាក្យរើសអើង ជាពាក្យដែលមានលក្ខណៈជាប្រមាថ លោកមានស្គាល់ពាក្យហ្នឹងទេ?

**ឆ៖** សូមអរគុណលោកមេធាវី។ ខ្ញុំអាចបង្ហាញលោកចេញពីប្រភពនៅក្នុងសៀវភៅរបស់ខ្ញុំដែលជាកំណត់ត្រាដែលបានធ្វើការសម្ភាសយ៉ាងជ្រៅជ្រះ ល្អិតល្អន់។ ឈ្មោះ ឆ្លាត ម្នាក់គឺថាមនុស្សដែលឆ្លាត ជាមនុស្សមួយគឺថារឹងមាំ គាត់ប្រាប់ខ្ញុំអំពីជីវិតរបស់គាត់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ នៅពេលដែលគាត់ គឺថាគេឈឺចាប់ណាស់ ដោយសារថាគាត់ជាប្រជាជនថ្មី គាត់មានការបាត់បង់យ៉ាងសម្បើមនៅពេលនោះ។ គាត់បាត់បង់បងប្រុសរបស់គាត់ ហើយគាត់រៀបរាប់ប្រាប់ខ្ញុំទាំងយប់ទាំងថ្ងៃ ហើយគេយកបងគាត់ហ្នឹង យកទៅបាត់ កូនចៅបងគាត់ទៅបាត់។ ពីរបីថ្ងៃក្រោយមក ឃើញគេយកខោអាវបងរបស់គាត់ហ្នឹង យកមកចែកឲ្យគេស្លៀកពាក់។ អ៊ីចឹងបើលោកមើលទំព័រណាមួយឲ្យបានជាក់លាក់នោះ មានថ្ងៃមួយ គាត់បានយកប្រធានបទនេះ អំពីបញ្ហាជនជាតិវៀតណាមនេះ យកមកប្រាប់ខ្ញុំ ហើយគាត់ធ្វើការពន្យល់ខ្ញុំអំពីការស្អប់ជនជាតិយួនប្រាប់ខ្ញុំម្ដងហើយម្ដងទៀត ម្ដងហើយម្ដងទៀត។ អ៊ីចឹងយោងទៅលើអ្វីដែលលោកសួរខ្ញុំ គឺថាខ្ញុំបានជួបប្រទះ និងសាកសួរប្រជាជនដែលមានការអប់រំរៀនសូត្រខ្ពស់ ចំពោះការប្រើប្រាស់ពាក្យនេះ។ ហើយបើលោកចង់ពិនិត្យមើលឲ្យបានច្បាស់លាស់ គឺមាននៅក្នុងសៀវភៅរបស់ខ្ញុំហើយ និងបើសិនណាជាលោកចង់ពិនិត្យពិច័យឲ្យបានច្បាស់លាស់។

[១១:៣២:៣២]

**ស៖** បាទ អរគុណ។ ហើសម្រាប់លោកផ្ទាល់ លោកមានចាំទេ ពាក្យណាមួយដែលខ្មែរប្រើសម្រាប់ហៅយួន ក្នុងលក្ខណៈជាការប្រមាថនោះ លោកចាំពាក្យហ្នឹង ដោយផ្ទាល់ខ្លួនឯងទេ ឥឡូវនេះ?

**ឆ៖** សូមអរគុណលោកមេធាវី។ ដូចដែលខ្ញុំបានជម្រាបខាងដើម បើយើងមើលការផ្សព្វផ្សាយរបស់បក្សកុម្មុយនីស្ដកម្ពុជា កម្ពុជាប្រជាធិបតេយ្យ ពាក្យ "យួន" នេះគឺត្រូវបានប្រើប្រាស់ក្នុងរូបភាព

ញុះញង់យ៉ាងទូលំទូលាយ។ ក្នុងបរិបទនេះ ហើយយួននោះ គឺយកមកប្រើប្រាស់សំដៅទៅលើកងទ័ពវៀតណាម ដែលយល់ថាជាការគំរាមកំហែងដ៏សម្បើមមួយ ក៏ដូចជាសំដៅទៅលើជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជានៅពេលនោះ--

**ស៖** សូមទោសអ្នកជំនាញ សំណួរខ្ញុំខ្លីទេ ហើយច្បាស់លាស់បំផុត។ ខ្ញុំសួរថា លោកចាំទេពាក្យខ្មែរណាមួយដែលខ្មែរហៅយួន ក្នុងន័យជាការប្រមាថ? បើលោកចាំ លោកថាចាំ បើលោកមិនចាំទេ ក៏មិនអីដែរ ខ្ញុំនឹងសួរតទៅទៀត។

**ឆ៖** សូមអរគុណលោកមេធាវី។ ពាក្យដែលខ្ញុំធ្លាប់ឮជាញឹកញាប់ ជាពិសេសសំដៅទៅលើជនជាតិភាគតិចវៀតណាម នៅក្នុងពេលនោះគឺពាក្យ "យួន" ខ្ញុំនិយាយសំដៅទៅលើប្រជាជនដែលខ្ញុំបានសម្ភាស។ គាត់ប្រើប្រាស់នៅពេលហ្នឹង មិនមែនជារឿងមួយចម្លែកទេ គឺជាពាក្យដែលត្រូវបានផ្សព្វផ្សាយ ប្រើប្រាស់ រហូតដល់អ្នកនយោបាយក៏យកពាក្យនេះ យកមកប្រើប្រាស់ដែរ។ ហើយដែលទស្សនវិទូជាច្រើនដែលបាន ជាពិសេសនេះគឺពាក្យនេះ គេប្រើនៅជំនាន់អ៊ុនតាក់។ គឺវាមានការរីករាលដាលយ៉ាងខ្លាំង។ ក្នុងពេលខ្ញុំសម្ភាសនុ៎ង វាមានកត្តាអក្សរសាស្ត្រ វាមានការអះអាងចំពោះការប្រើពាក្យ "យួន" នេះ ថាគឺជាការប្រើប្រឆាំងទៅនឹងជនជាតិវៀតណាម មិនឲ្យមានមនោសញ្ចេតនាជាមួយវៀត-ណាមទេ។

[១១:៣៤:៥១]

**ស៖** បាទ សូមអរគុណ។ ខ្ញុំអាចសង្ខេបពីសក្ខីកម្មរបស់លោកអម្បាញ់មិញបានទេថា លោកអត់បានដឹងពាក្យណាផ្សេងក្រៅពីពាក្យហៅថា "យួន" នេះទេ ដែលពាក្យខ្មែរប្រើសម្រាប់សំដៅទៅលើជនជាតិយួនក្នុងលក្ខណៈជាការប្រមាថ លោកអត់មានចាំទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** សូមអរគុណលោក។ ជាថ្មីម្តងទៀត ខ្ញុំមិនដែលធ្វើសេចក្តីសន្និដ្ឋានថា ពាក្យនេះត្រូវបានប្រើប្រាស់ ដោយសារនៅកម្ពុជា ជួនកាលគេប្រើពាក្យ "ឆ្កែ"នេះ សំដៅទៅលើមនុស្សដែលគេបន្ទាបបន្ថោកតម្លៃ។ ជួនកាលគេប្រើពាក្យថា "កន្ទុយម៉ែអាឆ្កែយួន"។ ដូចដែលខ្ញុំបានជម្រាបអ៊ីចឹង គឺពេលដែលខ្ញុំមកប្រទេសកម្ពុជា ខ្ញុំធ្វើការសិក្សាស្រាវជ្រាវពាក្យនេះ គឺដែលជាការឆ្លុះបញ្ចាំងនូវបទពិសោធន៍របស់គាត់នៅពេលនោះ។

**ស៖** បាទ សូមអរគុណ។ ពាក្យៗលោកនិយាយអំមិញ ថែមពាក្យថា "អាឆ្កែ" ហើយបើនិយាយទៅពាក្យថា "អាឆ្កែ" នេះជាពាក្យជេរ។ បើអ៊ីចឹងទោះបីពាក្យនៅពីក្រោយហ្នឹងស្អីក៏ដោយ គឺថា

ពាក្យ "អាឆ្កែ" ពីមុខហើយ គឺវាអត់មានល្អទេ។ តើលោកយល់អ៊ីចឹងទេ?

**ឆ៖** សូមអរគុណលោកមេធាវីការពារក្តី។ បាទ លោកអាចបូកពាក្យចូលគ្នា ដូចជាសំដៅទៅលើជនជាតិវៀតណាមថាជានរក។ ហើយបើមើលទៅឯកសារខ្មៅ និយាយអំពីសារជាតិរបស់អាយួនដែលវាពាក់ព័ន្ធទៅនឹង ភ្ជាប់ទៅនឹងពាក្យដទៃទៀត ដែលគេត្រូវបានយកមកប្រើប្រាស់ ហើយដោយមិនយោងទៅលើបរិបទអ្វីនោះឡើយ។ ប៉ុន្តែបើយើងមើលទៅលើបរិបទដ៏ទូលំទូលាយក្នុងការញុះញង់ និងបរិបទកម្ពុជាប្រជាធិបតេយ្យ វាច្បាស់លាស់ណាស់ថា ការប្រើពាក្យ "យួន" នៅពីនោះ នៅពេលនោះ គឺជាពាក្យដែលគេឃោសនា ដើម្បីឲ្យចងកំហឹង ស្អប់ ជាពិសេសក្នុងសុន្ទរកថាដែលគេបានប្រើប្រាស់នាសម័យនោះ រហូតដល់ឆ្នាំ៧៨។ ណាយ៉ាន់ ចាន់ដា ក៏បានលើកបញ្ហានេះយកមកនិយាយផងដែរ។ ពេលហ្នឹង គឺសំដៅតើធ្វើម៉េច គេថាគឺថាស្អប់យួន ហើយបើសិនមានការវាយប្រហារហ្នឹង សម្លាប់យួនហ្នឹងគេៗសម្លាប់បែបដូចគេហៅថាសត្តឃាតយ៉ាងដូច្នោះឯង។ ហើយវាក៏ភ្ជាប់--

[១១:៣៧:៤៦]

**ស៖** សូមទោសលោកអ្នកជំនាញ ខ្ញុំត្រូវកាត់លោក ដោយសារពេលវេលាវាកាន់តែហួសច្រើននាទីហើយ។ ហើយខ្ញុំចង់សួរលោកអម្បាញ់មិញនេះ គឺទាក់ទងនឹងពាក្យឯករាជ្យ ដែលប្រើសំដៅទៅលើយួន ជាជនជាតិយួនជាទូទៅ មិនមែនអាការប្រើពាក្យបូក ហើយនៅតែពាក្យយួនដដែលទេ។ ខ្ញុំចង់សួរអំពីពាក្យដោយឡែកមួយដែលគេប្រើ ខ្មែរប្រើជំនួសពាក្យថា "យួន" នេះ ហើយដែលមានន័យដូចគ្នានឹងយួនដែរ ប៉ុន្តែវាមានលក្ខណៈប្រមាថ។ អានេះដែលៗខ្ញុំចង់សួរលោក តែលោកអត់បានឆ្លើយតបនឹងខ្ញុំទេ។ អ៊ីចឹងខ្ញុំសូមសួរទៅសំណួរផ្សេងទៀត។ ខ្ញុំចង់សួរបញ្ជាក់លោកថា នៅក្នុងសម័យសង្គ្រាមជាពិសេសក្នុងទសវត្សរ៍៧០ ក្នុងដំណាក់កាលអាចមុន ឬក៏ក្រោយហ្នឹង ថាតើប្រទេសកម្ពុជាស្ថិតនៅក្រោមឥទ្ធិពលនៃសង្គ្រាមត្រជាក់ដែរឬទេក្នុងពេលនោះ?

**ឆ៖** សូមអរគុណលោកមេធាវី។ ខ្ញុំគិតថាវាច្បាស់ហើយ ដើម្បីឲ្យបញ្ហានេះទៅមុខរលូន សូមលោកសួរសំណួរត្រង់ៗតែម្តងមក។

**ស៖** បាទ សំណួរបន្ទាប់ទៀត ខ្ញុំចង់សួរបញ្ជាក់លោកថា តើប្លុកកុម្មុយនីស្ត ហើយនិងប្លុកខាងសេរីបានប្រើប្រាស់កម្ពុជាជាទីលានប្រយុទ្ធមួយ ដើម្បីផលប្រយោជន៍អ្វី បើសិនជាលោកយល់ថាកម្ពុជាគឺស្ថិតនៅក្នុងឥទ្ធិពលនៃសង្គ្រាមត្រជាក់នោះ?

[១១:៣៩:៤៣]

**ឆៈ** សូមអរគុណលោកមេធាវីការពារក្ដី។ ការបកប្រែអត់ច្បាស់ទេលោក។ ដូច្នេះសូមលោកសួរសំណួរឡើងវិញ។

**សៈ** បាទ សំណួររបស់ខ្ញុំ គឺទាក់ទងទៅនឹងការប្រើប្រាស់ទឹកដីកម្ពុជាក្នុងលក្ខណៈនៃការដណ្ដើមផលប្រយោជន៍គ្នារវាងប្លុកសេរី និងប្លុកកុម្មុយនីស្ដ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើវាមានកត្តាអ្វីដែលៗនាំឲ្យភាគីទាំងពីរ ខាងកុម្មុយនីស្ដ និងខាងសេរីប្រើប្រាស់កម្ពុជាដើម្បីទាញកម្ពុជាឲ្យធ្លាក់ចូលទៅក្នុងសង្គ្រាមត្រជាក់នេះ?

**ឆៈ** សូមអរគុណលោកមេធាវីការពារក្ដី។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ ដូចខ្ញុំបានលើកឡើងពីខាងដើម បើលោកមើលពីក្របខ័ណ្ឌនៃអំពើប្រល័យពូជសាសន៍ លោកក៏ត្រូវមើលអំពីកត្តាសេដ្ឋកិច្ច កត្តាសង្គមកិច្ចដែលវាពាក់ព័ន្ធគ្នា កត្តាដទៃទៀតដែលពាក់ព័ន្ធ ហើយក្នុងបរិបទកម្ពុជា កត្តាមួយ គឺវាពាក់ព័ន្ធនឹងកត្តានយោបាយ វាពិតជាដូចសំណួរលោកហើយ គឺអ៊ីចឹងគេយកអ៊ីចឹងមែន។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ខ្ញុំជឿថាលោកបានជជែកខាងដើមខ្លះហើយ ខ្ញុំគ្រាន់តែចង់សួរបញ្ជាក់ដោយខ្លីថា តើមានផលប៉ះពាល់អ្វីទេ ដល់សង្គមកម្ពុជានាសម័យនោះ ដោយសារតែការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក?

[១១:៤១:៣៣]

**ឆៈ** សូមអរគុណលោកមេធាវី។ ពិតណាស់ខ្ញុំបានរៀបរាប់នៅក្នុងសៀវភៅហើយ ក្នុងដំណើរការដែលវាមានបញ្ហាសង្គមកិច្ច សេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជា កត្តាមួយដែលពាក់ព័ន្ធនៅក្នុងដំណើរការនេះ គឺការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិក ដែលចាប់ផ្ដើមតាំងពីមុនឆ្នាំ១៩៧០ ហើយបន្តរហូតមកដល់ឆ្នាំ១៩៧៣។ វាមិនមែនជាមូលហេតុដែលនាំឲ្យអំពើហិង្សាទេ ក៏ប៉ុន្តែវាជាមូលហេតុមួយដែលនាំឲ្យខ្មែរក្រហមមានឱកាសចូលមកកាន់អំណាច ដោយសារតែប្រជាជនហ្នឹង បាត់បង់ផ្ទះសម្បែង ទ្រព្យរបស់ខ្លួន ដោយសារតែការទម្លាក់គ្រាប់បែកនេះឯង។ ដូច្នេះការទម្លាក់គ្រាប់បែកនេះ វានាំឲ្យមានការខឹងសម្បារកាន់តែខ្លាំងឡើងៗ ហើយក៏វាជាកត្តាមួយដែលនាំឲ្យខ្មែរក្រហមមានឱកាសឡើងមកកាន់អំណាច ហើយអំពើប្រល័យពូជសាសន៍នេះ ក៏វាកើតឡើងចេញមកពីដោយសារកត្តានៃការទម្លាក់គ្រាប់បែកនេះផងដែរមើលទៅ។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការបង្កើតបក្សឥណ្ឌូចិន តើលោកយល់ស្របទេថាខាងថ្នាក់ដឹកនាំវៀតណាមក្នុងសម័យនោះ គឺមានបំណងបង្កើតបក្សឥណ្ឌូចិន ដែលមានក្រោមការដឹកនាំ

របស់វៀតណាមក្នុងប្រទេសបីគឺ កម្ពុជា ឡាវ និងវៀតណាម ហើយដែលបក្សឥណ្ឌូចិន នេះគឺដឹកនាំជាចម្បងដោយមានទាំងគេហៅថា ទាំងនយោបាយទាំងកងទ័ព ទាំងប្រទេស ហើយអាចរហូតដល់ទៅចាយប្រាក់ ជាប្រាក់ ជាលុយក្រដាសប្រាក់ បក្សឥណ្ឌូចិននេះទៀតផង។ តើលោកយល់ស្របអ៊ីចឹងទេ?

[១១:៤៣:៣៣]

**ឆ៖** សូមអរគុណលោកមេធាវី។ លោកបានរាប់បញ្ចូលចំណុចជាច្រើន ប៉ុន្តែខ្ញុំអាចបញ្ជាក់ថាដំណាក់កាលដំបូងៗ នៃការបង្កើតសហព័ន្ធឥណ្ឌូចិនដែលដឹកនាំដោយវៀតណាម ដែលបក្សឥណ្ឌូចិននេះពិតហើយ គឺថាត្រូវបានបង្កើតឡើងដោយហូជីមិញ។

**ស៖** បាទ សូមអរគុណ។ សំណួរមួយទៀត ទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យ ខ្ញុំចង់សួរលោកថា ក្រោយជ័យជម្នះ ១៧ មេសា ១៩៧៥ តើលោកអាចកំណត់បានទេថា អ្វីជាសេចក្ដីត្រូវការសំខាន់របស់កម្ពុជានៅពេលនោះ?

**ឆ៖** សូមអរគុណលោកមេធាវីការពារក្ដី។ តម្រូវការជាចាំបាច់ នាពេលនោះ ខ្ញុំមិនច្បាស់លាស់ថាលោកកំពុងនិយាយពីអ្វី កំពុងនិយាយអំពីការៗ ចង់និយាយថាការធ្វើម៉េចរក្សាការពារម្ហូបអាហារ ការផ្គត់ផ្គង់ឲ្យបាន ឬក៏យ៉ាងណា ព្រោះថានេះវាមាននៅក្នុងសំណុំរឿង០០២/០១ ហើយ។ គេអាចបកស្រាយសំណួរលោកទៅតាមរូបភាពផ្សេងៗ ចំពោះពាក្យថា “តម្រូវការជាចាំបាច់” នៅពេលនោះៗ។ អ៊ីចឹងខ្ញុំសូមឲ្យលោកសួរឲ្យបាន ឲ្យច្បាស់លាស់។ សួររបៀបនេះគឺថាមានលក្ខណៈទូលំទូលាយបន្តិច។

**ស៖** បាទ ត្រឹមត្រូវហើយ។ ខ្ញុំសូមសួរសំណួរចុងក្រោយមួយ គឺទាក់ទងចំណុចនេះដដែល។ តើលោកយល់ស្របទេ ទៅលើការអនុវត្តនយោបាយកសិកម្ម ដើម្បីលើកកម្ពស់សេដ្ឋកិច្ច ក៏ដូចជាខាងម្ហូបអាហារ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ប្រជាជនកម្ពុជានៅក្នុងដំណាក់កាលនៃរបបនៃកម្ពុជាប្រជាធិបតេយ្យ?

[១១:៤៥:៥៨]

**ឆ៖** សូមអរគុណលោកមេធាវីការពារក្ដី។ ដូចខ្ញុំបានលើកឡើងខាងដើម ខ្ញុំជឿជាក់ថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ខ្មែរក្រហមគឺថាទស្សនទានថា ចង់ឲ្យសង្គមនេះមានយុត្តិធម៌ និងភាពជឿនលឿនឡើង ដោយធ្វើការកែទម្រង់សង្គម។ ហើយនៅពេលហ្នឹងហើយ ដែលនាំឲ្យឈានទៅដល់ការលុបបំបាត់ក្រុមមួយចំនួន ដោយសារថាក្រុមខ្លះហ្នឹង គឺថាបង្កភាពល្អក់កករមកដល់សង្គម។ ខ្ញុំបានរៀបរាប់

ប្រាប់ហើយថា ត្រូវតែពិនិត្យពិច័យឲ្យបានល្អិតល្អន់ទៅលើកត្តាសង្គម កត្តាសេដ្ឋកិច្ច។ ខ្ញុំប្រើពាក្យអង់គ្លេសថា *“ម៉ាកឃើង ឌិហ្វេរិន”* គឺថាភាពខុសគ្នា ដោយការកំណត់ក្រុមណាមួយ ភាពខុសគ្នាដោយការរៀបចំរចនាសម្ព័ន្ធឡើងវិញ ហើយនិងត្រូវពិនិត្យទៅលើអ្វីដែលបានកើតមានឡើងនៅពេលនោះ។ ទស្សនៈនៅពេលនោះ គឺថាថ្នាក់ដឹកនាំ គឺថាចង់ឲ្យសង្គមកម្ពុជាហ្នឹងមានភាពប្រសើរឡើងហ្នឹង ហើយដោយសារតែធ្វើបែបហ្នឹង បានទើបឈានទៅដល់ប្រព្រឹត្តអំពើប្រល័យពូជសាសន៍។

**លោក គង់ សំអុន៖**

សូមអរគុណអ្នកជំនាញ។ ហើយសូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះបានស្តាប់សំណើសុំចុងក្រោយមួយរបស់មេធាវីការពារក្តីលោក នួន ជា ថាលោក នួន ជា មានបំណងធ្វើប្រតិកម្ម ថ្លែងប្រតិកម្មតបទៅនឹងសក្ខីកម្មរបស់អ្នកជំនាញរូបនេះ ហើយអាចប្រើប្រាស់ពេលវេលាក្នុងរយៈ១០ ទៅ ១៥នាទី។ ហើយអង្គជំនុំជម្រះក៏សូមបញ្ជាក់ផងដែរថា សួរបញ្ជាក់ទៅថា តើលោក នួន ជា អាចឡើងមកធ្វើសេចក្តីថ្លែងការណ៍ប្រតិកម្មតបទៅនឹងសក្ខីកម្មរបស់អ្នកជំនាញនៅក្នុងបន្ទប់សវនាការបានដែរទេ ព្រោះព្រឹកមិញយើងបានសម្រេចអំពីបញ្ហាថា គាត់លះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ?

[១១:៤៧:៥៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ជាការពិតហើយ ខ្ញុំបានទាក់ទងទៅគាត់ ហើយគាត់ថាគាត់ត្រៀមខ្លួនរួចរាល់ហើយ លោកប្រធាន។ ឥឡូវនេះម៉ោងវាកៀកនឹងម៉ោងដប់ពីរទៅហើយលោកប្រធាន។ ដោយសារថា លោក ខៀវ សំផន គឺថា គាត់ត្រូវការពេលវេលាសម្រាក ប៉ុន្តែលោក នួន ជា វិញត្រៀមខ្លួនរួចជាស្រេច ដើម្បីឡើងមកខាងលើនេះ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី យើងខ្ញុំសុំសួរទៅមេធាវីការពារក្តីថា តើ នួន ជា លះបង់សិទ្ធិមិនឆ្លើយតប ឬក៏យ៉ាងម៉េច? ហើយឥឡូវនេះគាត់នឹងសាកសួរទៅលើភាគី គឺអ្នកជំនាញ។ សុំធ្វើការពន្យល់ឲ្យបានច្បាស់លាស់ចំណុចនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

គាត់លះបង់សិទ្ធិ តែឥឡូវនេះគាត់សុំបះបង់ចោលនូវការលះបង់សិទ្ធិព្រឹកមិញហ្នឹង ដើម្បីមកឆ្លើយតបជាមួយអ្នកជំនាញ។ អ៊ីចឹងគាត់បើកជំហរខ្លួនគាត់នេះ អ៊ីចឹងគាត់សុំៗ គឺថាសុំទទួលសិទ្ធិដែលគាត់បានលះបង់មកវិញ ដើម្បីមកឆ្លើយតបទៅនឹងអ្នកជំនាញ។

**លោក វីល្លៀម ស្មីត៖**

ដូច្នេះអាស្រ័យទៅលើអង្គជំនុំជម្រះ ដែលជនជាប់ចោទត្រូវមកបង្ហាញសក្ខីកម្ម មកតតាំងដោយសារថាគាត់បានលះបង់សិទ្ធិរួចទៅហើយ។ ហើយបើមិនដូច្នេះទេ អ្វីដែលជនជាប់ចោទឡើងមកនិយាយ ក៏វាមិនមានអត្ថន័យអ្វីដែរ ពីព្រោះប្រព័ន្ធច្បាប់ស៊ីវិលថា នៅក្នុងសវនាការលើកដំបូងនេះ នៅពេលដែលបះបង់សិទ្ធិបែបនេះ ភាគីមិនអាចសួរទៅជនជាប់ចោទបាន។ ដូច្នេះ សូមមេត្តាអង្គជំនុំជម្រះពិចារណា ថាតើយើងអនុវត្តប្រព័ន្ធនេះបានដោយរបៀបណា?

[១១:៥០:១៦]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ដោយសារតែគេលើកឡើងអំពីបញ្ហាសុខភាពរបស់កូនក្តីរបស់ខ្ញុំ អ៊ីចឹងខ្ញុំសូមបញ្ជាក់ថា ប្រសិនបើមិនមានសវនាការនៅរសៀលនេះទេ គាត់អាចប្រឹងប្រែងបន្តនៅព្រឹកនេះបានទៅទៀត ប្រសិនបើអង្គជំនុំជម្រះសម្រេចថានឹងស្តាប់លោក នួន ជា នាពេលឥឡូវនេះនោះ។

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការ។ ខ្ញុំ សុន អរុណ មេធាវីរបស់លោក នួន ជា។ ខ្ញុំបានទៅជជែកគ្នាជាមួយនឹងលោក នួន ជា ច្រើនដង ព្រឹកនេះ គាត់ស្តាប់ គាត់មើលទូរទស្សន៍រាល់ពេល ហើយគាត់ឃើញយើងសវនាការនេះជជែកគ្នាពាក្យ "យួន"។ ដូចលោកមេធាវី គង់ សំអុន បានជម្រាប និងសួរទៅខាងអ្នកជំនាញព្រឹកមិញអ៊ីចឹង។ គាត់ឃើញជជែកគ្នាពីរឿងយួន មិនដាច់ស្រេច ហើយអ្នកជំនាញនៅតែជម្លោះពីរឿងការពារថា កាលណានិយាយពាក្យ "យួន" ទុកដូចជាការមើលងាយ។ គាត់សូមមកបំភ្លឺ គាត់ដឹងរឿងហ្នឹងច្បាស់ ថាយួនកើតពីត្រឹមណា ពាក្យ "យួន" ហ្នឹង? ហើយកើតចេញពីកន្លែងណា? ហើយនិងពេលណាខ្លះដែលគេត្រូវការនិយាយថាពាក្យ "យួន"? អាហ្នឹងគាត់ចង់មកបំភ្លឺទេ។ បើសិនតុលាការអនុញ្ញាត គាត់នឹងមក។ បើអត់ទេ ថាអ្ហែ! មិនសំខាន់ទេ គាត់ក៏អត់មកដែរ។ សូមអរគុណ។

[១១:៥១:៥២]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវហ្នឹងដើម្បីសម្រួលបញ្ហាហ្នឹងទាំងអស់គ្នា អង្គជំនុំជម្រះក៏ធ្លាប់បានស្តាប់នូវប្រតិកម្មរបស់លោក នួន ជា ច្រើនលើកច្រើនសាដែរកន្លងមក។ ហើយបញ្ហាទី២ គឺខាងលោក ខៀវ សំផន គាត់បានបង្ហាញហើយថា មិនមានបញ្ហាអីទេ គាត់អាចបន្តបញ្ចប់ដើម្បីគាត់មានឱកាសសម្រាកនៅរសៀលនេះ។ ដូច្នេះអង្គជំនុំជម្រះសម្រេចថា ស្តាប់នូវប្រតិកម្មតបរបស់លោក នួន ជា ចំពោះសក្ខីកម្មរបស់អ្នកជំនាញ ហ៊ីនតុន នៅពេលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា ឡើងមកកាន់បន្ទប់សវនាការ។

*(ជនជាប់ចោទ នួន ជា ចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះកុំឲ្យខាតពេល អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោក នួន ជា ដើម្បីប្រតិកម្មតបទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ ហើយអ្នកជំនាញចូរស្តាប់នូវប្រតិកម្មតបរបស់លោក នួន ជា ចំពោះសក្ខីកម្មរបស់លោកដែលបានផ្តល់សក្ខីកម្មរយៈពេលបីថ្ងៃកន្លះកន្លងមកនេះ។ ហើយក្នុងករណីចាំបាច់អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅអ្នកជំនាញ ដើម្បីធ្វើការឆ្លើយតបចុងក្រោយ។

សូមអញ្ជើញលោក នួន ជា!

[១១:៥៨:៤២]

**លោក នួន ជា៖**

អរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំមកបំភ្លឺ ខ្ញុំសូមបំភ្លឺទេ ព្រោះខ្ញុំស្តាប់ទៅដូចជាទាស់ត្រចៀកបន្តិចរឿងជាមួយអ្នកជំនាញ។ ពាក្យ "យួន" ខ្ញុំបានទៅបើកមើលវចនានុក្រមខ្មែររបស់សម្តេច ជួន ណាត គ្រិស្តសករាជ១៩៦៧ ពុទ្ធសករាជ២៥១១ ទំព័រ៩៥៥ បន្ទាប់ទី៥។ ពាក្យយួន គឺជានាម ជាតិមនុស្សអ្នកដែនតុងកឹង ដែនអណ្ណាម ដែនកូសាំងស៊ីន ហៅថាយួនតឹងក័ង យួនអណ្ណាម យួនកូសាំងស៊ីន។ ពាក្យសាមញ្ញច្រើនហៅយួនតុងក័ងថា យួនហាណូយ ហៅយួនអណ្ណាមថាយួនហ្វេ ហៅយួនកូសាំងស៊ីន ថាយួនព្រៃនគរ។ ដូច្នោះកម្ពុជាប្រជាធិបតេយ្យនេះ មិនមែនទៅចង់ទៅញុះញង់អីអ្នកណាទេ។ ខ្ញុំសូមជម្រាបអ៊ីចឹង វចនានុក្រមនិយាយអ៊ីចឹងច្បាស់។

ឯតមកទៀត ប៉ុល ពត គាត់បានណែនាំថា យើងកុំហៅ គេជាសត្រូវស្លូតបូត ពីព្រោះវៀតណាម

ជាមិត្ត ប៉ុន្តែមានទំនាស់។ នេះព្រោះ ប៉ុល ពត គាត់បញ្ជាក់ជំហរគាត់ច្បាស់លាស់ណាស់។ មិត្តមានទំនាស់។ ទំនាស់អី គាត់មិនថាទេ។ នេះខ្ញុំសូមជម្រាបត្រង់ហ្នឹង។ ដូច្នេះពាក្យដែលខ្មែរ ទុកយួនជាសត្រូវសួពូជ។ ក៏ប៉ុន្តែ ប៉ុល ពត គាត់តម្រង់ ថាកុំ ជាមិត្តមានទំនាស់។ អានេះខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត ដើម្បីឲ្យបំភ្លឺ។

តទៅនេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ខ្ចីប៉ុណ្ណឹងហ្នឹងទេ។ ដូច្នេះគ្មានទៅញុះញង់ ចាក់រុកអីណាទេ។ ឯរឿងដែលថា ប្រជាជនមានប៉ុណ្ណោះលាន យួនប៉ុណ្ណោះលាន បើវ៉ៃយួនប៉ុណ្ណោះ ម្នាក់វ៉ៃឲ្យយួនងាប់ប៉ុណ្ណោះៗ អាហ្នឹងក៏ខុសទៀត។

[១២:០១:១៦]

និយាយខាងផ្លូវយោធា ប៉ុល ពត គាត់និយាយថា យើងប្រើសង្គ្រាមឈ្លប យកតូចវ៉ៃធំ។ បើយួន ១០០នំ យើងតែ១០នាក់បានហើយ ព្រោះយើងគ្មានកម្លាំងទេ យើងកម្លាំងតូច។ ម្នាក់! បើយើងបាញ់យួនឲ្យរបួសម្នាក់ វាត្រូវសែង៤នាក់។ ចុះបើយើងបាញ់វា១០នាក់ វាសែងអស់ប៉ុន្មាន? ៤០នាក់ទៅហើយ។ ដូច្នោះ គាត់និយាយនេះ ដើម្បីលើកជាមាគ៌ាសង្គ្រាមឈ្លបរបស់កម្ពុជាប្រជាធិបតេយ្យពេលនោះ។ មិនមែនទៅសម្លាប់ប្រជាជនយួនស៊ីៗណានោះទេ។ នេះ ខ្ញុំសូមជម្រាបតែប៉ុណ្ណឹង។

ឥឡូវខ្ញុំចូលដល់សំណួរ។ ខ្ញុំសូមចង់សួរអ្នកជំនាញ តើវៀតណាម រហូតមកដល់បច្ចុប្បន្ននេះ តើបោះបង់ចោលមហិច្ឆតាឈ្លានពាន វាតទី លេបទឹកដី បំបាត់ពូជសាសន៍កម្ពុជាហើយឬនៅ? មួយ។ ទី២ លោកជំនាញជាជាតិអាមេរិក តើរដ្ឋាភិបាលអាមេរិកទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាចំនួន៣០០ថ្ងៃ ៣០០យប់ ៣លានតោន បំផ្លាញផ្ទះសម្បែង វត្តអារាម ផ្លូវថ្នល់ និងសម្លាប់ប្រជាជនស្លូតត្រង់រាប់សែននាក់ តើវាជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាមឬទេ? សូមអស់ប៉ុណ្ណឹង។ សូមគោរពលោកប្រធាន។

[១២:០២:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមផ្តល់វេទិកាជូនទៅលោកអ្នកជំនាញ ដើម្បីឆ្លើយតបទៅនឹងសំណួរ ក៏ដូចជាតបទៅនឹងអ្វីដែលជាប្រតិកម្មតបរបស់លោក នួន ជា ចំពោះលោក ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

កុំអាលទាន់!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូ -- អ៊ំ លោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សេចក្តីថ្លែងដែលទើបលើកឡើងអម្បាញ់មិញដោយលោក នួន ជា មិនត្រឹមត្រូវទៅនឹងអ្វីដែលអ្នកជំនាញលើកមកជាភស្តុតាងនោះទេ។ អ្នកជំនាញ គឺគាត់បានសួរឲ្យអ្នកជំនាញឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ ជាក់ស្តែងនោះ គឺថាអ្នកជំនាញមិនបានចូលពិនិត្យមើលភស្តុតាងព័ត៌មានទាំងអស់ក្នុងសំណុំរឿងទេ។ ជាពិសេសឯកសារដែល នួន ជា គាត់យោងនោះ។ សំណួរនោះសួរថា តើអ្នកជំនាញគួរតែឆ្លើយដោយមិនទាន់បានពិនិត្យមើលទៅលើព័ត៌មាននេះសិន ឬក៏យ៉ាងណា? នេះទៅតាមមតិ ហើយនិងសំណួររបស់លោក នួន ជា។ នួន ជា គាត់បានលើកឡើងថា ប៉ុល ពត មិនដែលនិយាយថា យួន គឺជាខ្មាំងទេ។

[១២:០៤:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឲ្យអង្គជំនុំជម្រះកុំលើក -- ឈប់ឲ្យផ្តល់សក្ខីកម្ម វាទៅជាសហព្រះរាជអាជ្ញាឡើងផ្តល់សក្ខីកម្មទៅវិញ។ បាទ លោក ហ៊ីនតុន នេះជាអ្នកជំនាញអាចនឹងមានចំណេះដឹងក្នុងការធ្វើប្រតិកម្មទៅនឹងសំណួររបស់គាត់បានហើយ។

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំរៀបនឹងសួរទៅអង្គជំនុំជម្រះ ក៏ប៉ុន្តែដោយសារមេធាវីការពារក្តីឡើងជំទាស់ខ្ញុំ។ បើយើងនិយាយពីសុន្ទរកថា យើងបានស្តាប់ឮជាច្រើនហើយ ពីភាគីកាលពីម្សិលមិញ សូមផ្តល់ឧទាហរណ៍មួយ។ ខ្ញុំសូមសួរសំណួរនេះទៅកាន់អង្គជំនុំជម្រះ ក្នុងករណីដែល នួន ជា និយាយថា ប៉ុល ពត មិនដែលនិយាយថា វៀតណាម ឬក៏យួនគឺជាសត្រូវនេះទេ ខ្ញុំសូមលើកយកនូវឯកសារចុះថ្ងៃទី០២ ឆ្នាំ៧៩ ឯកសារ E3/8404, អង់គ្លេស ERN 00419728, ខ្មែរ 00716183, បារាំង 00017542។ នេះជាសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី០២ ខែមករា ៧៩ ដែលនិយាយថា ប្រជាជនកម្ពុជាប្រឆាំងទៅនឹងវៀតណាមដែលជាសត្រូវស្លូតបូត។ ដែលនេះជាផ្ទុយទៅនឹងអ្វីដែល នួន ជា ទើបលើកឡើងអម្បាញ់មិញនេះ។ ចំណុចរបស់ខ្ញុំគឺថា តើអង្គជំនុំជម្រះចង់ឲ្យអ្នកជំនាញផ្តល់មតិយោបល់ឆ្លើយតបដោយគាត់មិនបានមើលទៅលើឯកសារទាំងឡាយណា ដែលជាឯកសារវាថ្លែងទៅផ្ទុយទៅនឹងអ្វីដែល នួន ជា កំពុងតែលើកឡើងនេះ។ ដូច្នេះភាគីទាំងអស់ ឥឡូវនេះកំពុងស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ។

[១២:០៦:២៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ចំពោះអ្វីដែលសហព្រះរាជអាជ្ញាលើកឡើង។ ទី១ គាត់ឥឡូវហ្នឹងកំពុងតែបញ្ចុកចំណីទៅអ្នកជំនាញហើយ បញ្ចុកពាក្យចូលទៅឲ្យអ្នកជំនាញ។ ទី២ បើសិនណាជាមានការប្រើពាក្យហ្នឹង ខ្ញុំសូមជំទាស់ ដោយវៀតណាមបានឈ្លានពានកម្ពុជាជាមួយកងទ័ពយ៉ាងច្រើនរហូតដល់ ១៥០.០០០នាក់។ ពិភពលោកទាំងមូលគេដឹងថា ដោយសារមានការគាំទ្រពីសហភាពសូវៀត ពេលនោះប្រហែលជាសារតែខឹងសម្បារហើយ ទើបទៅប្រើពាក្យហ្នឹង ដោយសារតែការឈ្លានពាននេះឯង។

**ប្រធានអង្គជំនុំ៖**

យើងបានប្រើពាក្យពេចន៍អំមិញគឺថា ផ្តល់ឱកាសទៅឲ្យអ្នកជំនាញ ដើម្បីគាត់មានលទ្ធភាពធ្វើប្រតិកម្មតប ឬក៏ឆ្លើយតប ប្រសិនបើគាត់មានបំណងធ្វើដូច្នេះ។ បើគាត់មិនមានបំណងធ្វើ ក៏មិនអីដែរ ពីព្រោះបញ្ហាវាបានសួរដេញដោលរួចហើយ ហើយក្របខ័ណ្ឌសំណួរចុងក្រោយ គឺក្រៅពីវិសាលភាពនៃអង្គហេតុដែលអង្គជំនុំជម្រះធ្វើសវនាការចោទប្រកាន់ទៅលើជនជាប់ចោទផង ហើយក៏ទំនងជាក្រៅពីវិសាលភាពនៃភាពជំនាញរបស់អ្នកជំនាញរូបនេះ ដែលអង្គជំនុំជម្រះបានកំណត់មកស្តាប់សក្ខីកម្មនៅក្នុងអំឡុងសវនាការប៉ុន្មានថ្ងៃនេះ។

សូមអញ្ជើញលោកអ្នកជំនាញ!

[១២:០៨:០៨]

**លោក អាឡិចសាន់ឌឺ ហ៊ីនតុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏សូមអរគុណជនជាប់ចោទ ដែលបានឡើងមកខាងលើ ហើយបង្ហាញនូវទស្សនៈនេះ គឺយើងខ្ញុំថាសំខាន់ណាស់ ថាគេបានស្តាប់ឮគ្រប់គ្នាហើយនូវមតិ នូវយោបល់របស់គាត់នេះ។ ហើយគាត់មានទស្សនទានរបស់គាត់ដោយឡែក។ នៅក្នុងកិច្ចដំណើរការនីតិវិធីនេះដំបូង សូមអរគុណ ថ្លែងអំណរគុណចំពោះរូបគាត់សិន។ ជនជាប់ចោទបានសួរខ្ញុំពីរបីសំណួរ ហើយខ្ញុំនឹងឆ្លើយខ្លីៗទេ។ ពាក់ព័ន្ធទៅនឹងសំណួរអំពីថាតើវៀតណាម គឺជាខ្មាំងយូរអង្វែង ឬយ៉ាងម៉េច? គេបានពិភាក្សានៅក្នុងកិច្ចដំណើរការនីតិវិធីហើយ ថាការយល់ឃើញបែបនេះ គឺជាបទដ្ឋានមួយដែលបានកើតមានឡើងដោយបំភ្លេចនូវកត្តាប្រវត្តិសាស្ត្រ ពេលវេលា ក៏ដូចជាភាពខុសគ្នាពិសេសៗមួយចំនួន គឺជាពិសេសពាក់ព័ន្ធទៅនឹងស្ថានភាពប្រវត្តិសាស្ត្រ និងនយោបាយដ៏ស្មុគស្មាញ ហើយម្នាក់ៗគឺថាផ្តោះទៅរក

គោលដៅរបស់ខ្លួន។ ខ្ញុំសូមឆ្លើយថា ករណីនេះមិនដូចគាត់ថាដូច្នេះទេ។ ទាក់ទងទៅនឹងសំណួរទី២ អំពីការទម្លាក់គ្រប់បែកសហរដ្ឋអាមេរិក គឺថាអ្នកដែលគេនិយាយថាជាការរំលោភទៅលើច្បាប់អន្តរជាតិហើយ។ វាមានផលប៉ះពាល់យ៉ាងខ្លាំង។ គ្មានអ្នកណាម្នាក់អាចជំទាស់តវ៉ាបានទេ។ ហើយដូចខ្ញុំនិយាយថា ការទម្លាក់គ្រាប់បែកនេះជាផ្នែកមួយនៃកម្តៅ ដែលនាំឲ្យកម្ពុជាប្រជាធិបតេយ្យ ជាពិសេសនៅពេលដែលប្រជាជនកម្ពុជាគេត្រូវចាត់ទុកថា ជាខ្មាំងវណ្ណៈ វិទ្ធង្សនា ប្រឆាំងបដិវត្តន៍ ហើយដែលវានាំឲ្យកើតមាននូវអំពើប្រល័យសាសន៍។

ជាថ្មីម្តងទៀត គួរតែមានពាក្យពេចន៍ចុងក្រោយបញ្ជាក់ឲ្យបានច្បាស់លាស់។ ខ្ញុំរីករាយណាស់ដែលការពិភាក្សាពីពាក្យ “យួន” អាចនឹងនាំឲ្យមានការគិតគូរឲ្យបានជ្រៅជ្រះ វាជាពាក្យមួយដែលគេយកមកប្រើប្រាស់ជាទូទៅ ក៏ប៉ុន្តែ នៅចុងបញ្ចប់ ជំហររបស់ខ្ញុំគឺថា បញ្ជាក់យ៉ាងច្បាស់ថា ពាក្យ “យួន” អាចជាពាក្យប្រើប្រាស់ន័យខុសៗគ្នា ជាពាក្យដែលអាចញុះញង់ឲ្យមានកំហឹង និងអំពើហិង្សា ហើយក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ គឺជាពាក្យដែលញុះញង់ ឲ្យកើតមាននូវអំពើប្រល័យពូជសាសន៍ហើយ។ សូមអរគុណលោកប្រធាន សូមអរគុណលោក នួន ជា។

[១២:១១:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអរគុណដល់អ្នកជំនាញ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះសវនាការលើកទៅបន្តធ្វើនៅថ្ងៃច័ន្ទ ទី២១ ខែមីនា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃច័ន្ទ និងថ្ងៃអង្គារ ខែមីនា ឆ្នាំ២០១៦ សប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សារណាផ្ទាល់មាត់របស់ភាគី ស្តាប់បន្ថែម ស្តាប់សក្ខីកម្មសាក្សីបន្ថែម ឬក៏ជំនួសពាក់ព័ន្ធជាមួយនឹងអង្គហេតុចោទប្រកាន់ មន្ទីរសន្តិសុខភ្នំក្រោលរបស់សហព្រះរាជអាជ្ញា ហើយនិងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-900 ពាក់ព័ន្ធទៅនឹងអង្គហេតុចោទប្រកាន់អូរកន្សែងតាមរយៈប្រព័ន្ធសោតទស្សន៍ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះសូមអរគុណលោកសាស្ត្រាចារ្យ អ្នកជំនាញ អាឡិចសាន់ដឺ ឡាបាន ហ៊ីនតុន ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃ ធ្វើដំណើរមកពីទីឆ្ងាយឯនាយសមុទ្រមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សី ក្នុងរយៈពេលបីថ្ងៃកន្លះកន្លងមកនេះ ប្រកបដោយភាពអំណត់អត់

ធ្ងត់ គុណធម៌ និងសីលធម៌វិជ្ជាជីវៈកម្រិតខ្ពស់។ ហើយសក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានដ៏សំខាន់ នៅក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយសវនាការស្តាប់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកសាស្ត្រាចារ្យមានសុខភាពល្អ បានសេចក្តីសុខ សេចក្តីចម្រើន និងទទួលបានជោគជ័យថ្មីៗថែមទៀត ហើយនិងធ្វើដំណើរត្រឡប់ទៅប្រកបដោយសុវត្ថិភាព។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោកសាស្ត្រាចារ្យ ហ៊ីនតុន វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃច័ន្ទ ទី២១ ខែមីនា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១២:១៣ នាទី)*